## នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
## នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| **សំណុំរឿងលេខ** | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| **ដាក់ទៅ** | : | អង្គជំនុំជម្រះសាលាដំបូង |
| **ថ្ងៃដាក់** | : | ថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៦ |
| **ភាគីអ្នកដាក់** | : | សហព្រះរាជអាជ្ញា |
| **ភាសាដើម** | : | អង់គ្លេស |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 02-May-2016, 16:00
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សម្ងាត់**

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះ: សម្ងាត់/Confidential

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្ដោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

# ចម្លើយតបរបស់សហព្រះរាជអាជ្ញានៅនឹងសំណើរបស់ នួន ជា សុំប្រើប្រាស់ចម្លើយមន្ទីរសន្តិសុខ ស-២១ មួយចំនួន

---

**អ្នកដាក់ឯកសារ:**

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Nicholas KOUMJIAN

**អ្នកទទួលឯកសារ:**

**អង្គជំនុំជម្រះសាលាដំបូង**

ចៅក្រម និល ណុន, ប្រធាន

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម យ៉ា សុខន

ចៅក្រម Claudia FENZ

ចៅក្រម យូរ ឧត្តរា

**សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី:**

លោក ពេជ អង្គ

លោកស្រី Marie GUIRAUD

**ចម្លងជូន:**

**ជនជាប់ចោទ**

នួន ជា

ខៀវ សំផន

**មេធាវីការពារក្តីជនជាប់ចោទ:**

លោក សុន អរុណ

លោក Victor KOPPE

លោក គង់ សំអុន

លោកស្រី Anta GUISSÉ

លោក Arthur VERCKEN

## I. សេចក្តីផ្តើម

1. សហព្រះរាជអាជ្ញាសុំឆ្លើយតបទៅនឹងសំណើរបស់ នួន ជា អនុលោមតាមវិធាន៩២ នៃវិធានផ្ទៃក្នុង សុំប្រើប្រាស់ចម្លើយមន្ទីរសន្តិសុខ ស-២១ មួយចំនួន[1] ដែលរូបគាត់ស្វែងរកការអនុញ្ញាតពីអង្គជំនុំជម្រះសាលាដំបូង ("អង្គជំនុំជម្រះ") ប្រើប្រាស់ចម្លើយមន្ទីរសន្តិសុខ ស-២១ របស់ កុយ ធួន, យឹម សំបាត់, និង ជា នន់ *ហៅ* សួង[2]។ ជម្រើសផ្សេងទៀត គាត់បានស្នើសុំអង្គជំនុំជម្រះឱ្យធ្វើការស៊ើបអង្កេតបន្ថែមទៀតលើកាលៈទេសៈនានាដែលចម្លើយមន្ទីរសន្តិសុខ ស-២១ ទាំងនេះ ត្រូវបានទទួល មុនពេលអង្គជំនុំជម្រះធ្វើសេចក្តីសម្រេចលើការអនុញ្ញាតឱ្យប្រើប្រាស់ចម្លើយទាំងនេះ[3]។

2. សម្រាប់ហេតុផលនានាដែលបានរៀបរាប់ខាងក្រោមនេះ សហព្រះរាជអាជ្ញាជំទាស់ទៅនឹងការប្រើក្នុងសំណុំរឿង០០២/០២ នូវចម្លើយទាំងអស់ដែលបានផ្តល់ដោយបុគ្គលទាំងបីរូបនោះ លើកលែងតែក្នុងករណីដែលថា(ក) ការប្រើប្រាស់របស់វាមិនស្ថិតនៅក្នុងមាត្រា១៥ នៃអនុសញ្ញាប្រឆាំងនឹងទារុណកម្ម និងការប្រព្រឹត្តិមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ("CAT")[4] (ខ) ចម្លើយទាំងនេះត្រូវប្រើក្នុងលក្ខខណ្ឌមានកម្រិតដែលបានអនុញ្ញាតរួចហើយដោយអង្គជំនុំជម្រះនេះ[5]។ បន្ថែមលើនេះទៀត សហព្រះរាជអាជ្ញាយល់ឃើញថា មិនមានការស៊ើបអង្កេតណាបន្ថែមទៀតទៅលើកាលៈទេសៈនានា ដែលចម្លើយទាំងនេះត្រូវបានធ្វើឡើងដោយមិនចាំបាច់ និងមិនអាចអនុវត្តបាន។

3. ទោះបីជាការអះអាងរបស់ នួន ជា ផ្ទុយក៏ដោយ ក៏វានៅតែមាន "ហានិភ័យពិតប្រាកដ" ដែលចម្លើយរបស់បុគ្គលទាំងនេះ ត្រូវបានទទួលតាមរយៈការធ្វើទារុណកម្មផ្លូវកាយ និង/ឬផ្លូវចិត្ត ដែល

---

[1] **E399** សំណើរបស់ នួន ជា អនុលោមតាមវិធាន ៩២ នៃវិធានផ្ទៃក្នុង សុំប្រើប្រាស់ចម្លើយសារភាព ស ២១ មួយចំនួន, ២០ មេសា ២០១៦ ("សំណើរបស់ នួន ជា") (បានជូនដំណឹងជាភាសាអង់គ្លេស និងភាសាខ្មែរនៅថ្ងៃទី២០ ខែមេសា ឆ្នាំ២០១៦)។

[2] **E399** សំណើរបស់ នួន ជា, កថាខណ្ឌ ១៥-៣២។

[3] **E399** សំណើរបស់ នួន ជា, កថាខណ្ឌ៣២។ ក៏ប៉ុន្តែ សហព្រះរាជអាជ្ញាកត់សម្គាល់ថា នួន ជា បានធ្វើការសន្និដ្ឋានជាក់លាក់តែអំពីការស៊ើបអង្កេតបន្ថែមទៀតលើកាលៈទេសៈនានាដែលចម្លើយសារភាពមន្ទីរស-២១ របស់ ជា នន់ *ហៅ* សួង ត្រូវបានធ្វើឡើងតែប៉ុណ្ណោះ (**E399** សំណើរបស់ នួន ជា, កថាខណ្ឌ ៣០)។

[4] អនុសញ្ញាប្រឆាំងនឹងទារុណកម្ម និងការប្រព្រឹត្តិមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ("CAT") G.A. Res. 39/46, U.N. GAOR, 39th Sess., Supp. No. 51, U.N. Doc. A/RES/39/46, 1465 UNTS 113 (ឆ្នាំ១៩៨៤)។

[5] លក្ខខណ្ឌលើកលែងទាំងនេះត្រូវបានរៀបរាប់លម្អិតនៅក្នុងជើងទំព័រលេខ ១០។

ស្ថិតនៅក្នុងអត្ថន័យនៃមាត្រា ១ នៃ CAT និងច្បាប់ទំនៀមទម្លាប់អន្តរជាតិ។ មានភ័ស្តុតាងគួរឲ្យជឿជាក់បានថា កុយ ធួន ទទួលរងទារុណកម្មទាំងផ្លូវកាយ និងផ្លូវចិត្ត ក្នុងរយៈពេលនៃការសួរចម្លើយរបស់គាត់ "និងមានហានិភ័យពិតប្រាកដ" ដែលចម្លើយសារភាពរបស់ យឹម សំបាត់ និង ជា ណុង ហៅ សួង ជាផលមួយដែលបានមកពីការទទួលរង និងការឈឺចាប់ទាំងផ្លូវកាយ និងចិត្តធ្ងន់ធ្ងរ។ អង្គជំនុំជម្រះបានទទួលភ័ស្តុតាងគ្រប់គ្រាន់ដែលបង្ហាញថា ស-២១ គឺជាកន្លែងដែល "ដែលនាំឲ្យមានការឈឺចាប់ ឬរងទុក្ខយ៉ាងខ្លាំង ទោះផ្លូវកាយ ឬផ្លូវចិត្ត"[6]។ សូម្បីតែ អ្នកជាប់ឃុំមួយចំនួនតូចទាំងនោះ ប្រហែលជាចៀសផុតពីការធ្វើទារុណកម្មផ្លូវកាយ ជាពិសេសត្រូវបានអនុវត្តយ៉ាងជាក់លាក់ក្នុងអំឡុងពេលសួរចម្លើយ បានសារភាពដោយសារតែការឈឺចាប់ផ្លូវចិត្ត និងផ្លូវការយធ្ងន់ធ្ងរ ដែលពួកគេទទួលរងនៅមន្ទីរសន្តិសុខ ស-២១។ អ្នកសួរចម្លើយបានប្រើប្រាស់ការគាបសង្កត់ផ្លូវចិត្តយ៉ាងព្រៃផ្សៃ ដូចជា ការគំរាមកំហែង និងយុទ្ធវិធីចិត្តសាស្ត្រផ្សេងទៀត ដើម្បីបង្កការភ័យខ្លាច និងបំបាក់ស្មារតីរបស់ជនរងគ្រោះ។ ខណៈដែលអ្នកទោស ស-២១ តស៊ូរស់ក្នុងលក្ខខណ្ឌដ៏អាក្រក់ និងអមនុស្សធម៌នោះ ពួកគេបានទទួលរងជាប្រចាំនូវទិដ្ឋភាព ក្លិន និងសំឡេងនៃវិធីសាស្ត្រឃោរឃៅនៃទារុណកម្មផ្លូវកាយ និងផ្លូវចិត្តដែលបានប្រើនៅទីនោះ និងការដឹងថាវិធានការទាំងនោះអាចត្រូវបានប្រើមកលើខ្លួននៅពេលវេលាណាមួយ។

4. ការប៉ុនប៉ងរបស់ នួន ជា ដើម្បីពឹងផ្អែកលើចម្លើយសារភាពដែលបានមកពីមន្ទីរសន្តិសុខ ដែលបានពឹងផ្អែកជាប្រព័ន្ធទៅនឹងការធ្វើទារុណកម្មសាហាវក្នុងអំឡុងពេលសួរចម្លើយនោះ គឺពិតជាអ្វីដែល CAT មានគោលបំណងហាមឃាត់ -- គឺការប្រើប្រាស់ភ័ស្តុតាងដែលបានមកពីការធ្វើទារុណកម្មដើម្បីធ្វើយុត្តិកម្មការឃុំខ្លួន និងវិធានការផ្សេងៗដែលមន្ទីរសន្តិសុខស-២១បានប្រើប្រឆាំងនឹងបុគ្គលដែលត្រូវបានធ្វើទារុណកម្ម។

## II. ច្បាប់ដែលអាចអនុវត្តបាន

5. មាត្រា១៥ នៃអនុសញ្ញាប្រឆាំងទារុណកម្ម ("CAT") ចែងថា៖

> កំណត់ហេតុណាមួយដែលបង្កើតឡើងបានមកពីអំពើទារុណកម្ម មិនត្រូវយកមកសម្អាងជាភស្តុតាងក្នុងនីតិវិធីណាមួយឡើយ លើកលែងតែប្រឆាំងនឹងបុគ្គលម្នាក់ដែលត្រូវបានចោទប្រកាន់ថាបានធ្វើទារុណកម្មនៅពេលធ្វើចម្លើយនោះ។

[6] CAT, មាត្រា ១។

6. អង្គជំនុំជម្រះនេះបានបញ្ជាក់ថា ការប្រើប្រាស់ភ័ស្តុតាងដែលបានមកដោយការធ្វើទារុណកម្ម ដើម្បីបញ្ជាក់ពីសច្ចភាពនៃបញ្ហាដែលបានអះអាង ឧទាហរណ៍ តាមរយៈការផ្ទាញ់សាក្សីជាមួយនឹងចម្លើយសារភាពដើម្បីបញ្ជាក់ ឬបដិសេធអង្គហេតុនានាដែលមាននៅក្នុងនោះ មិនត្រូវបានអនុញ្ញាតឡើយ[7]។ ស្រដៀងគ្នានេះដែរ ការយោងទៅលើចម្លើយនានាដែលមាននៅក្នុងចម្លើយសារភាពមន្ទីរ ស-២១ ដោយមិនមានការកំណត់អត្តសញ្ញាណថាព័ត៌មានបែបនោះបានមកពីចម្លើយសារភាព គឺមិនត្រូវបានអនុញ្ញាតឡើយ[8]។ ជាងនេះទៀត អង្គជំនុំជម្រះនេះបានសម្រេចថាការអានដោយផ្ទាល់នៅក្នុងតុលាការនូវចម្លើយដែលបានមកពីការធ្វើទារុណកម្ម ដោយមិនគិតអំពីចេតនានៃការធ្វើដូច្នេះ នាំឱ្យមានការចាប់អារម្មណ៍ថាវាកំពុងត្រូវបានប្រើដើម្បីបង្កើតសច្ចភាពរបស់ចម្លើយនោះ ហើយហេតុដូច្នេះ មិនគួរត្រូវបានទទួលយកដោយអង្គជំនុំជម្រះនោះឡើយ[9]។ អង្គជំនុំជម្រះក៏បានបញ្ជាក់ផងដែរអំពីការប្រើប្រាស់ម្លើយសារភាពពីមន្ទីរស-២១ មួយចំនួន ដែលត្រូវបានអនុញ្ញាត[10]។

*បទដ្ឋាន និងបន្ទុកនៃភ័ស្តុតាង*

7. អង្គជំនុំជម្រះតុលាការកំពូល (“អជតក”) បានរកឃើញថា បទដ្ឋាននៃភ័ស្តុតាងដែលត្រូវអនុវត្តទៅលើការសម្រេចថាតើត្រូវបាន “បង្ហាញ” ថាចម្លើយត្រូវបានធ្វើឡើង ដោយលទ្ធផលនៃការធ្វើទារុណកម្មសម្រាប់គោលបំណងនៃវិធានបដិសេធភ័ស្តុតាងក្នុងមាត្រា១៥ របស់ CAT នោះ គឺថាតើមាន “ហានិភ័យពិតប្រាកដ” នៃការធ្វើទារុណកម្ម ឬទេ ដែលចម្លើយនោះបានមកពី

[7] **E350/8** សេចក្តីសម្រេចលើភ័ស្តុតាង ដែលបានមកដោយការធ្វើទារុណកម្ម, ៥ កុម្ភៈ ២០១៦ (“សេចក្តីសម្រេច អជសដ ស្តីពីទារុណកម្ម”), កថាខណ្ឌ៨៥ និង៨៨។

[8] **E350/8** សេចក្តីសម្រេច អជសដ ស្តីពីទារុណកម្ម, កថាខណ្ឌ ៨២។

[9] **E350/8** សេចក្តីសម្រេច អជសដ ស្តីពីទារុណកម្ម, កថាខណ្ឌ ៨៨។

[10] **E350/8** សេចក្តីសម្រេច អជសដ ស្តីពីទារុណកម្ម, កថាខណ្ឌ ៨១, ៨៤, ៨៧។ ភាគីអាចប្រើប្រាស់ចម្លើយសារភាពនៅមន្ទីរ ស-២១ ក្នុងករណីដែល៖ (១) សំណួរយោងទៅលើចំណារ ឬសួរអំពីព័ត៌មានអត្តសញ្ញាណជាមូលដ្ឋាន (ដូចជា ប្រវត្តិរូប)។ (២) ចម្លើយសារភាពដែលបានមកដោយអំពើទារុណកម្មមិនត្រូវបានសួរទៅសាក្សី ដើម្បីបញ្ជាក់អង្គហេតុ ហើយសំណួរផ្តោតទៅលើការដឹងរបស់សាក្សី។ ជាងនេះទៀត សំណួរទៅកាន់សាក្សីដោយផ្អែកលើសៀវភៅកំណត់ហេតុ ឬ សៀវភៅបញ្ជី ឈ្មោះអ្នកជាប់ឃុំពីមន្ទីរសន្តិសុខនានាដែលមានគំនិត និងទស្សនៈនៃការធ្វើទារុណកម្មអាចអនុញ្ញាតបាន ដរាបណាឯកសារទាំងនោះមិនត្រូវបានប្រើដើម្បីបង្ហាញពីសច្ចភាពរបស់ចម្លើយដែលធ្វើឡើងដោយអ្នកដែលទទួលរងទារុណកម្មនោះទេ។ ឧទាហរណ៍ ប្រសិនបើវាអាចបង្ហាញថា បុគ្គលដែលត្រូវបានរៀបរាប់ ក្រោយមកត្រូវបានចាប់ខ្លួន ឬសម្លាប់ចោលនោះ វាអាចប្រើជាការបញ្ជាក់អំពីការពឹងផ្អែកលើព័ត៌មាននេះដោយជនជាប់ចោទ ឬអ្នកដទៃទៀតនៅក្នុងរច្ចនាសម្ព័ន្ធ បកក។

ទារុណកម្ម[11]។ ស្រដៀងគ្នានេះដែរ អង្គជំនុំជម្រះនេះក៏បានចាត់ទុក “ហានិភ័យពិតប្រាកដ” ជាបទដ្ឋាននៃភស្តុតាងដែលអាចអនុវត្តបានផងដែរ ក្នុងការសម្រេចថាតើភស្តុតាងជាក់លាក់ចាំបាច់ត្រូវដកចេញដោយសំអាងលើការធ្វើទារុណកម្ម ឬយ៉ាងណា[12]។ អង្គជំនុំជម្រះបានបញ្ជាក់ថា ខ្លួននឹង “ពិចារណាលើភស្តុតាងទៅតាមករណីជាក់ស្ដែងនីមួយៗ ដើម្បីសម្រេចថាតើមានហានិភ័យពិតប្រាកដដែរ ឬយ៉ាងណា ដែលថាភស្តុតាងបានមកដោយការធ្វើទារុណកម្ម”[13] និងថាការវាយតម្លៃបឋមថាតើភស្តុតាងបានមកដោយការធ្វើទារុណកម្មដែរឬយ៉ាងណានោះ គឺជាបន្ទុករបស់អង្គជំនុំជម្រះ[14]។

8. ទាំង អជតក និង អង្គជំនុំជម្រះនេះបានរកឃើញថា “ហានិភ័យពិតប្រាកដ” នោះ កើតមានទាក់ទងនឹងចម្លើយនានាដែលប្រមូលបានពីអ្នកជាប់ឃុំនៅមន្ទីរ ស-២១។ រំលឹកពីការយល់ឃើញអំពី “ការធ្វើទារុណកម្ម ការធ្វើបាបលើរូបកាយ និងការឈឺចាប់ផ្លូវចិត្ត” នៅមន្ទីរ ស-២១ ដែលខ្លួនគាំទ្រក្នុងសំណុំរឿង០០១ នោះ[15] អជតក ជឿជាក់ថាមានហានិភ័យពិតប្រាកដដែលចម្លើយនៅមន្ទីរ ស-២១ ក្នុងបញ្ហានេះ បានមកពីការធ្វើទារុណកម្ម *និងចម្លើយនីមួយៗអាចត្រូវបានសន្មតយ៉ាងដូច្នោះទាំងអស់*[16]។ អង្គជំនុំជម្រះនេះបានរកឃើញស្រដៀងគ្នានេះរួចហើយថា “ហានិភ័យពិតប្រាកដដែលថាចម្លើយសារភាពណាដែលធ្វើនៅមន្ទីរសន្តិសុខ ស-២១ សុទ្ធតែបានមកដោយអំពើទារុណកម្ម”[17]។

9. យ៉ាងណាក៏ដោយ ភាគីណាក៏ដោយដែលបានស្វែងរកពឹងផ្អែកលើភស្តុតាងបែបនេះ អាចជំទាស់ទៅនឹងការកំណត់ដំបូងនេះ ជាពិសេស គឺការបង្ហាញនូវកាលៈទេសៈជាក់លាក់ដែលបដិសេធនូវហានិភ័យនេះ[18]។ អជតក បានសម្រេចថា “ចម្លើយនៅមន្ទីរ ស-២១ អាចត្រូវបានទទួលយកជា

---

[11] **F26/12** សេចក្ដីសម្រេចលើសេចក្ដីជំទាស់ទៅនឹងបញ្ជីឯកសារសំអាងហេតុពេញលេញ (“សេចក្ដីសម្រេច អជតក”), ៣១ ធ្នូ ២០១៥, កថាខណ្ឌ ៥៥-៥៦។

[12] **E350/8** សេចក្ដីសម្រេច អជសដ ស្ដីពីទារុណកម្ម, កថាខណ្ឌ ៣៣-៣៥។

[13] **E350/8** សេចក្ដីសម្រេច អជសដ ស្ដីពីទារុណកម្ម, កថាខណ្ឌ៣៥។ មើលផងដែរ កថាខណ្ឌ ៨៨។

[14] **E350/8** សេចក្ដីសម្រេច អជសដ ស្ដីពីទារុណកម្ម, កថាខណ្ឌ ៣៦។

[15] **F26/12** សេចក្ដីសម្រេច អជតក, កថាខណ្ឌ៥៦-៥៧។

[16] **F26/12** សេចក្ដីសម្រេច អជតក, កថាខណ្ឌ ៥៧។ សូមមើលផងដែរ កថាខណ្ឌ៥៦។

[17] **E350/8** សេចក្ដីសម្រេច អជសដ ស្ដីពីទារុណកម្ម, កថាខណ្ឌ ៧៩។

[18] **E350/8** សេចក្ដីសម្រេចអំពីទារុណកម្មរបស់ អជសដ, កថាខណ្ឌ៣៦។ **F26/12** សេចក្ដីសម្រេចរបស់ អជតក, កថាខណ្ឌ៥៨។

ភស្តុតាងតែក្នុងករណីដែលចម្លើយនេះ បានបង្ហាញឲ្យឃើញថា ផ្អែកលើបទដ្ឋានស្តីពីតុល្យភាពនៃភវនីយភាព *ពុំមែន* ជាលទ្ធផលនៃការធ្វើទារុណកម្មឡើយ”[19]។ អង្គជំនុំជម្រះបានសម្រេចថា “បន្ទាប់ពីធ្វើការវាយតម្លៃទៅលើគ្រប់កាលៈទេសៈដែលពាក់ព័ន្ធទាំងអស់ អង្គជំនុំជម្រះនឹងកំណត់ថាតើមានហានិភ័យពិតប្រាកដ ដែលថាភស្តុតាងនោះត្រូវបានទទួលតាមរយៈការធ្វើទារុណកម្មដែរឬទេ”[20]។ ដូច្នេះ ការប្រើប្រាស់ភស្តុតាងបែបនេះ គឺមិត្រូវបានអនុញ្ញាតឡើយ លើកលែងតែភាគីដែលស្នើសុំប្រើប្រាស់នូវភស្តុតាងនោះ បង្ហាញថា “ហានិភ័យពិតប្រាកដ” មិនកើតមាន ដែលថាវាត្រូវបានទទួលតាមរយៈការធ្វើទារុណកម្ម ឬវាស្ថិតនៅក្នុងករណីលើកលែងដែលមានចែងក្នុងមាត្រា១៥[21]។

*និយមន័យនៃទារុណកម្ម*

10. មាត្រា១នៃ អនុសញ្ញាប្រឆាំងទារុណកម្ម បានផ្តល់និយមន័យដល់ “ទារុណកម្ម” ដូចតទៅ៖

> អំពើទាំងឡាយណា ដែលនាំឲ្យមានការឈឺចាប់ ឬរងទុក្ខយ៉ាងខ្លាំង ទោះផ្លូវកាយ ឬផ្លូវចិត្តក្តី ដែលត្រូវបានបង្កឡើងដោយចេតនាទៅលើជនណាម្នាក់ ក្នុងគោលបំណងទាំងឡាយដូចជាទាញយកព័ត៌មាន ពីជននោះ ឬតតិយជនណាម្នាក់ ដាក់ទណ្ឌកម្មជននោះ ចំពោះអំពើណាមួយដែលជននោះ ឬតតិយជនណា ម្នាក់បានប្រព្រឹត្ត ឬសង្ស័យថាបានប្រព្រឹត្ត ឬបំភិតបំភ័យ ឬបង្ខិតបង្ខំជននោះ ឬតតិយជនណាម្នាក់ ឬដើម្បី មូលហេតុណាផ្សេងទៀត ដែលផ្អែកលើការរើសអើងណាមួយ បើការឈឺចាប់ ឬការរងទុក្ខ បង្កដោយមន្ត្រី សាធារណៈ ឬជនផ្សេងទៀត តាមការញុះញង់ ឬការព្រមព្រៀង ឬផ្តើមគំនិតរបស់មន្ត្រីសាធារណៈ ឬជន ផ្សេងទៀតដែលបំពេញតួនាទីជាផ្លូវការ។ ពាក្យទារុណកម្ម មិនរាប់បញ្ចូលនូវការឈឺចាប់ ឬការរងទុក្ខ ដែលកើតជាប់ ឬម្តងម្កាលពីទណ្ឌកម្មត្រឹមត្រូវតាមច្បាប់ឡើយ។

11. ដោយពឹងផ្អែកលើ CAT និងយុត្តិសាស្ត្រពីតុលាការ ICTY និង ICTR អង្គជំនុំជម្រះនេះបានរកឃើញថា ទារុណកម្ម ដែលជាបញ្ញានៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ រួមមាន “ការបង្កឲ្យមានការឈឺចាប់ ឬរងទុក្ខធ្ងន់ធ្ងរ *លើរាងកាយ ឬស្មារតី* ដោយអំពើសកម្ម ឬអកម្ម”[22]។ ឧក្រិដ្ឋកម្ម

---

[19] **F26/12** សេចក្តីសម្រេចរបស់ អជតក, កថាខណ្ឌ៥៨ (សង្កត់ន័យបន្ថែមដោយ*អក្សរទ្រេត*)។

[20] **E350/8** សេចក្តីសម្រេចអំពីទារុណកម្មរបស់ អជសជ, កថាខណ្ឌ៣៨។

[21] **E350/8** សេចក្តីសម្រេចអំពីទារុណកម្មរបស់ អជសជ, កថាខណ្ឌ៧៩, ទំព័រ ៣៣-៣៤។

[22] សាលក្រមសំណុំរឿង០០១-**E188** សាលក្រមរបស់ ឌុច, កថាខណ្ឌ ៣៥៣-៣៥៤ (សង្កត់ន័យ បន្ថែមដោយ*អក្សរទ្រេត*) *ដោយលើកឡើងពី Kunarac,* សំណុំរឿង IT-96-23 & IT-96-23/1-A, អង្គជំនុំជម្រះសាលា ឧទ្ធរណ៍, សាលដីកា, ១២ មិថុនា ២០០២ (“សាលដីការបស់ *Kunarac* ”), កថាខណ្ឌ១៤២, ១៤៦។ *Ntagerura,* សំណុំរឿង ICTR-99-46-T, អង្គជំនុំជម្រះសាលាដំបូង, សាលក្រម, ២៥ កុម្ភៈ ២០០៤, កថាខណ្ឌ៧០៣។ *Delalić,* សំណុំរឿង IT-96-21-T,

នៃទារុណកម្មតម្រូវថា អំពើសកម្ម ឬអកម្ម ត្រូវបានធ្វើឡើងក្នុងគោលបំណង ដើម្បីបានទទួលលទ្ធផល ឬដើម្បីគោលបំណងជាក់លាក់ណាមួយ[23]។

12. នៅក្នុងការកំណត់ថាតើអំពើ ឬការខកខានណាមួយបង្កើតបាន គឺជាការឈឺចាប់ដ៏ធ្ងន់ធ្ងរ ឬជាវេទនាដែរឬអត់នោះ តម្រូវឲ្យអង្គជំនុំជម្រះពិចារណាលើគ្រប់កត្តាអត្តនោម័ត និងសត្យានុម័តទាំងអស់[24]។ កត្តាសត្យានុម័ត រួមមានភាពធ្ងន់ធ្ងរនៃការឈឺចាប់ដែលបានបង្ក។ ចំណែកលក្ខណៈវិនិច្ឆ័យផ្នែកកត្តាអត្តនោម័ត អាចរួមបញ្ចូលទាំង វ័យ ភេទ ស្ថានភាពសុខភាពរបស់ជនរងគ្រោះ ឬអនុភាពនៃការប្រព្រឹត្តិផ្នែករាងកាយ និងផ្លូវចិត្តលើជនរងគ្រោះជាក់លាក់ណាមួយ[25]។ ជាការបន្ថែម ប្រភេទ និងបរិបទនៃការបង្កឲ្យមានការឈឺចាប់ ចេតនាគិតទុកជាមុន និងស្ថាបនកម្មនៃការប្រព្រឹត្តអំពើបន្ទាបបន្ថោក លក្ខខណ្ឌផ្លូវរាងកាយរបស់ជនរងគ្រោះ របៀប និងវិធីសាស្ត្រដែលគេបានប្រើ និងជំហរទន់ខ្សោយរបស់ជនរងគ្រោះ ទាំងអស់នេះសុទ្ធតែជាកត្តាដែលពាក់ព័ន្ធ[26]។ មិនមានការចាត់ថ្នាក់គ្រប់ជ្រុងជ្រោយនៃអំពើនានា ដែលអាចបង្កើតបានជាអំពើទារុណកម្មនោះទេ[27]។ វិបាកដែលកើតចេញពីអំពើ ឬការខកខាននេះ មិនចាំបាច់ទាល់តែគេអាចមើលឃើញជាក់ស្តែងនៅលើជនរងគ្រោះឡើយ[28] ហើយក៏គ្មានលក្ខខណ្ឌតម្រូវណាមួយដែលថាព្យសនកម្មនោះមានលក្ខណៈ

---

អង្គជំនុំជម្រះសាលាដំបូង, សាលក្រម, ១៦ វិច្ឆិកា ១៩៩៨ ("សាលក្រមរបស់ *Čelebići*"), កថាខណ្ឌ៤៥៩។ *Furundžija*, សំណុំរឿង IT-95-17/1-A, អង្គជំនុំជម្រះសាលាឧទ្ធរណ៍, សាលដីកា, ២១ កក្កដា ២០០០, កថាខណ្ឌ១១១។ *Furundžija*, សំណុំរឿង IT-95-17/1-T, អង្គជំនុំជម្រះសាលាដំបូង, សាលក្រម, ១០ ធ្នូ ១៩៩៨, កថាខណ្ឌ ១៦០-១៦១។

23 សាលក្រមសំណុំរឿង០០១-**E188** សាលក្រមរបស់ ឌុច, កថាខណ្ឌ៣៥៦, *ដោយលើកឡើងពី Krnojelac*, សំណុំរឿង IT-97-25-T, អង្គជំនុំជម្រះសាលាដំបូង, សាលក្រម, ១៥ មីនា ២០០២ ("សាលក្រមរបស់ *Krnojelac*"), កថាខណ្ឌ១៨០។

24 សាលក្រមសំណុំរឿង០០១-**E188** សាលក្រមរបស់ ឌុច, កថាខណ្ឌ ៣៥៥, លើកយោងរឿងក្តី *Kvočka*, សំណុំរឿង IT-98-30/1-T, អង្គជំនុំជម្រះសាលាដំបូង, សាលក្រម, ២ វិច្ឆិកា ២០០១ ("សាលក្រមសាលាដំបូងរបស់ *Kvočka*"), កថាខណ្ឌ ១៤៣។

25 សាលក្រមសំណុំរឿង០០១-**E188** សាលក្រមរបស់ ឌុច, កថាខណ្ឌ ៣៥៥, លើកយោង សាលក្រមសាលាដំបូងរបស់ *Kvočka*, កថាខណ្ឌ១៤៣។

26 សាលក្រមសំណុំរឿង០០១-**E188** សាលក្រមរបស់ ឌុច, កថាខណ្ឌ ៣៥៥, លើកយោង សាលក្រមសាលាដំបូងរបស់ *Krnojelac*, កថាខណ្ឌ១៨២។

27 សាលក្រមសំណុំរឿង០០១-**E188** សាលក្រមរបស់ ឌុច, កថាខណ្ឌ ៣៥៥, លើកយោងសាលក្រមសាលាដំបូងរបស់ *Čelebići*, កថាខណ្ឌ៤៦៩។

28 សាលក្រមសំណុំរឿង០០១-**E188** សាលក្រមរបស់ ឌុច, កថាខណ្ឌ ៣៥៥, លើកយោងសាលដីកាសាលាឧទ្ធរណ៍របស់ *Kunarac*, កថាខណ្ឌ១៥០។

ជាអចិន្ត្រៃយ៍ដែរ[29]។ អំពើទាំងឡាយដែលមានលក្ខណៈធ្ងន់ធ្ងរគ្រប់គ្រាន់ ដើម្បីបង្កើតបានជាទារុណកម្ម អំពើនោះអាចកើតចេញពីលក្ខខណ្ឌផ្សេងៗដែលគេបានដាក់ពេលជាប់ឃុំឃាំង និងដែលរួមបញ្ចូលទាំងការវាយដំ អំពើហិង្សាផ្លូវភេទ ការបដិសេធមិនឲ្យដេកយូរ ការបង្អត់អាហារ ការអនាម័យ និងជំនួយផ្នែកវេជ្ជសាស្ត្រ ព្រមទាំងការគំរាមកំហែងធ្វើទារុណកម្ម ឬការសម្លាប់សាច់ញាតិ[30]។ ការរស់នៅក្នុងស្ថានភាពភ័យខ្លាចជាប្រចាំ ដែលបង្កឡើងដោយការរំលោភបំពានផ្លូវកាយនិងការឃុំឃាំង បង្កើតបានជាទុក្ខវេទនាផ្លូវចិត្តដែលក្លាយជាទារុណកម្ម[31]។ ស្រដៀងគ្នានេះ ការគំរាមកំហេងធ្វើទារុណកម្មផ្លូវកាយដែលអាចជឿជាក់បាន អាចបង្កើតបានជាទារុណកម្មផ្លូវចិត្ត[32]។ លើសពីនេះ បុគ្គលម្នាក់អាចទទួលរងនូវគ្រោះថ្នាក់ផ្លូវចិត្តធ្ងន់ធ្ងរបាន តាមរយៈការមើលឃើញអំពើប្រឆាំងនឹងបុគ្គលម្នាក់ផ្សេងទៀត[33]។

---

[29] សាលក្រមសំណុំរឿង០០១-**E188** សាលក្រមរបស់ ឌុច, កថាខណ្ឌ ៣៥៥, លើកយោង សាលក្រមសាលាដំបូងរបស់ *Kvočka*, កថាខណ្ឌ១៤៨។ រឿងក្តី *Brđanin* IT-99-36-T, អង្គជំនុំជម្រះសាលាដំបូង, សាលក្រម, ១ កញ្ញា២០០៤, កថាខណ្ឌ ៤៨៤។

[30] សាលក្រមសំណុំរឿង០០១-**E188** សាលក្រមរបស់ ឌុច, កថាខណ្ឌ ៣៥៥, លើកយោង សាលក្រមសាលាដំបូងរបស់ *Čelebići*, កថាខណ្ឌ៤៦៧។ សាលក្រមសាលាដំបូងរបស់ *Kvočka*, កថាខណ្ឌ១៥១។ សូមមើលបន្ថែមទៀត ជើងទំព័រ៣២ ខាងក្រោម។

[31] *Hajrulahu ទល់នឹង សាធារណរដ្ឋម៉ាសេដូណៀ អតីតយូហ្គោស្លាវី,* ពាក្យសុំលេខ 37537/07, ECHR សាលដីកា (អង្គសេចក្តី និងសំណង) ២៩ មករា ២០១៦, កថាខណ្ឌ 101-102 ("តុលាការជឿថា ការចាប់ពង្រត់ និងការជាប់ឃុំឃាំងក្នុងផ្ទះមិនឲ្យប្រាស្រ័យទំនាក់ទំនងរបស់ម្ចាស់ពាក្យសុំរយៈពេលបីថ្ងៃ ដែលជាទីកន្លែងឃុំឃាំងវិសាមញ្ញមួយនៅខាងក្រៅក្របខណ្ឌតុលាការ ដែលបានរៀបចំឡើងដោយលាក់កំបាំង និងប្រតិបត្តិការដោយកម្លាំងសន្តិសុខរបស់រដ្ឋដែលឆ្លើយតប បានបំភិតបំភ័យម្ចាស់ពាក្យសុំដោយសារការជាប់ឃុំឃាំងរបស់គាត់ដោយសារគាត់មិនដឹងថានឹងមានអ្វីកើតឡើងចំពោះគាត់ នៅពេលបន្ទាប់ហើយដែលបានធ្វើឲ្យគាត់តប់ប្រមល់ខាងផ្លូវចិត្តនិងផ្លូវអារម្មណ៍។ គេមិនអាចប្រកែកបានឡើយថាគាត់បានរស់នៅក្នុងស្ថានភាពភ័យខ្លាចជាប្រចាំដោយសារតែភាពមិនប្រាកដប្រជាអំពីវាសនារបស់គាត់។ ការប្រព្រឹត្តពិតប្រាកដក្នុងអំឡុងនៃការសួរចម្លើយដែលគាត់ក៏ស្ថិតនៅក្នុងកម្មវត្ថុនោះដែរ ត្រូវតែត្រូវបានចាត់ទុកថាបានបង្កឲ្យមានការឈឺចាប់ ការភ័យខ្លាច ការប៉ះទង្គិចយ៉ាងធំធេងចំពោះរាងកាយ និងទុក្ខវេទនាផ្លូវចិត្ត។ តុលាការកត់សំគាល់ថា វិធានការដូចបានពោលខាងលើត្រូវបានគេប្រើប្រាស់បញ្ចូលគ្នា និងត្រូវបានធ្វើឡើងចំពោះតែម្ចាស់ពាក្យសុំក្នុងគោលបំណងដើម្បីទាញយកចម្លើយសារភាពអំពីការពាក់ព័ន្ធរបស់គាត់ នៅក្នុងឧប្បត្តិហេតុផ្ទុះគ្រាប់បែកដូចដែលគេបានចោទប្រកាន់ [...]។ តាមការយល់ឃើញរបស់តុលាការ ការប្រព្រឹត្តដូច្នេះមានតម្លៃស្មើនឹងការធ្វើទារុណកម្ម[...]")។

[32] សូមមើលជាឧទាហរណ៍ រឿងក្តី *Estrella ទល់នឹង Uruguay*, អង្គសេចក្តី, លេខប្រាស្រ័យទំនាក់ទំនង 74/1980, UN Doc CCPR/C/18/D/74/1980, IHRL 2557 (UNHRC 1983), ២៩ មីនា ១៩៨៣, គណៈកម្មាធិការសិទ្ធិមនុស្ស, កថាខណ្ឌ៨.៣ ("ពួកគេត្រូវបានគេនាំខ្លួនដោយរុំមុខ ទៅកាន់ទីកន្លែងមួយដែលគាត់បានស្គាល់សំឡេងរបស់[បុគ្គលពីរនាក់]។ ម្ចាស់អត្ថបទគឺជាកម្មវត្ថុនៃអំពើទារុណកម្មផ្លូវកាយ និងផ្លូវចិត្តយ៉ាងធ្ងន់ធ្ងរ រួមទាំងការគំរាមកំហែងកាត់ដៃម្ចាស់អត្ថបទដោយប្រើរណាយន្ត គេធ្វើ

*ការស៊ើបអង្កេតបន្ថែមទៀត*

13. តាមវិធាន[34] ៩៣(១) នៃវិធានផ្ទៃក្នុង "ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ការស៊ើបសួរថ្មីជាការចាំបាច់ អង្គជំនុំជម្រះសាលាដំបូងអាចបង្គាប់ឱ្យធ្វើការស៊ើបសួរបន្ថែមបានគ្រប់ពេលវេលា"។

## III. សេចក្តីសន្និដ្ឋាន

*ទារុណកម្មត្រូវបានគេប្រើជាប្រព័ន្ធដើម្បីទទួលបានចម្លើយសារភាពនៅមន្ទីរស-២១*

14. នួន ជា ស្វែងរកការប្រើប្រាស់ចម្លើយសារភាពរបស់ កុយ ធួន, យឹម សំបាត់ និង ជា នន់ *ហៅ* សួង ("សួង") ឈរលើមូលដ្ឋានដែលថា "ភ័ស្តុតាងបានបង្ហាញយ៉ាងច្បាស់ថាមិនមាន "ហានិភ័យពិតប្រាកដ" នៃការធ្វើទារុណកម្មនៅក្នុងករណី [ទាំងនេះ] ទេ"[35]។ គោលជំហរនេះមិនមានមូលដ្ឋានទាំងផ្នែកអង្គហេតុ និងផ្នែកគតិយុត្តិ។ ដូចបង្ហាញជាលម្អិតបន្ថែមទៀតខាងក្រោមនេះ មានភ័ស្តុតាងដែលគួរឱ្យជឿជាក់បាន និងជាក់លាក់ថា កុយ ធួន បានទទួលរងនូវ "ការឈឺចាប់

---

ដូច្នេះដើម្បីបង្ខំឱ្យគាត់សារភាពពីសកម្មភាពវិទ្ធង្សនា")។ សូមមើលផងដែរ កថាខណ្ឌ១.៦, ១០; *Martiza Urrutia ទល់នឹង Guatemala*, អង្គសេចក្តី, សំណង និងការចំណាយ, IACHR Series C No 103, IHRL 1486 (IACHR 2003), ២៧ វិច្ឆិកា ២០០៣, កថាខណ្ឌ 58.6, 85, 94 (ជនរងគ្រោះត្រូវបានគេ "បង្ហាញរូបថតបុគ្គលដែលមានស្នាមធ្វើទារុណកម្មលើខ្លួនប្រាណរបស់គេ ឬដែលត្រូវបានសម្លាប់នៅក្នុងពេលប្រយុទ្ធគ្នា ហើយនាងត្រូវបានគេគំរាមថា នឹងមានស្ថានភាពដូចគ្នានេះនៅពេលក្រុមគ្រួសាររបស់នាងរកឃើញនាង។ ភ្នាក់ងាររដ្ឋក៏បានគំរាមធ្វើទារុណកម្មលើរូបរាងកាយរបស់នាង ឬសម្លាប់នាង ឬសមាជិកគ្រួសារនាងផងដែរ ប្រសិនបើនាងមិនសហការ")។ តុលាការសិទ្ធិមនុស្សអន្តរអាមេរិកាំង បានរកឃើញថា "ខ្លួនមានភ័ស្តុតាងបញ្ជាក់ថា Maritza Urrutia បានទទួលរងនូវអំពើហិង្សាផ្លូវចិត្តតាមរយៈការដាក់សម្ពែងដោយចេតនាទៅនឹងបរិបទនៃការឈឺចាប់ និងការប៉ះទង្គិចដ៏តានតឹងមួយ យោងតាមការអនុវត្តជាធម្មតានាពេលនោះ[...]។ តុលាការក៏បានពិចារណាផងដែរថា អំពើដែលបានចោទប្រកាន់ក្នុងករណីនេះត្រូវបានរៀបចំ និងបង្កដោយចេតនាដើម្បីបំបាត់ដានបុគ្គលភាពរបស់ជនរងគ្រោះ និងធ្វើឱ្យខូចសីលធម៌របស់នាង ដែលទាំងនេះបង្កើតបានជាទម្រង់មួយនៃអំពើទារុណកម្មផ្លូវចិត្ត"។

[33] *Kayishema និង Ruzindana*, ICTR-95-1-T, អង្គជំនុំជម្រះសាលាដំបូង, សាលក្រម, ២១ ឧសភា ១៩៩៩, កថាខណ្ឌ១៥៣ ("អង្គជំនុំជម្រះគ្មានមន្ទិលទេថា ភាគីទីបីអាចទទួលរងគ្រោះថ្នាក់ផ្លូវចិត្តធ្ងន់ធ្ងរ តាមរយៈការឃើញអំពើដែលបានប្រព្រឹត្តប្រឆាំងនឹងបុគ្គលម្នាក់ផ្សេងទៀត")។

[34] អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អវតក"), វិធានផ្ទៃក្នុង (វិ.៩) ដែលបានពិនិត្យឡើងវិញនៅថ្ងៃទី១៦ ខែមករា ឆ្នាំ ២០១៥ ("វិធានផ្ទៃក្នុង") ឬ ("វិធាន")។

[35] **E399** សំណើរបស់ នួន ជា, កថាខណ្ឌ ៣១។ សូមមើលផងដែរ កថាខណ្ឌ ១។

និងទុក្ខវេទនាយ៉ាងធ្ងន់ធ្ងរទាំងផ្លូវកាយ ឬផ្លូវចិត្ត [ដែលគេ] បានបង្កឡើងដោយចេតនា[36] នៅក្នុងអំឡុងនៃដំណើរការសួរចម្លើយរបស់គាត់។ ភស្តុតាងក្នុងសំណុំរឿង០០២/០២ ព្រមទាំងការរកឃើញរបស់អង្គជំនុំជម្រះនេះក្នុងសំណុំរឿង០០១[37] បង្ហាញឲ្យឃើញថាសូម្បីតែមិនមានការបង្ខិតបង្ខំលើរាងកាយដោយផ្ទាល់ ទៅលើអ្នកទោសណាម្នាក់នៅក្នុងអំឡុងនៃការសួរចម្លើយដល់កម្រិតនៃការធ្វើទារុណកម្មក៏ដោយ ក៏លក្ខខណ្ឌនៃការឃុំខ្លួននៅមន្ទីរ ស-២១ និងការបង្ខិតបង្ខំផ្លូវចិត្តហួសហេតុដែលគេបានប្រើក្នុងអំឡុងនៃការសួរចម្លើយ រួមជាមួយនឹងការគំរាមកំហែងពិតប្រាកដ និងការគំរាមកំហែងដោយប្រយោលនៃការធ្វើទារុណកម្ម បើសិនជាចម្លើយ 'មិនពេញចិត្ត' ត្រូវបានផ្តល់ឲ្យដោយអ្នកទោស មានន័យថា មាន "ហានិភ័យពិតប្រាកដ" ថាចម្លើយសារភាពរបស់អ្នកដែលត្រូវបានសួរចម្លើយនៅមន្ទីរ ស-២១ ទទួលបានដោយការប្រើប្រាស់ ការធ្វើទារុណកម្មផ្លូវចិត្ត និងផ្លូវកាយ ដែលស្ថិតនៅក្នុងអត្ថន័យនៃមាត្រា១ របស់ CAT និងច្បាប់ទម្លាប់អន្តរជាតិដែរ។

15. អ្នកទោសនៅមន្ទីរ ស-២១ បានរស់នៅក្នុង "ស្ថានភាពភ័យខ្លាចជានិច្ច"[38]។ អ្នកទោសទាំងអស់ដែលឃុំនៅមន្ទីរស-២១ ត្រូវបានចាត់ទុកថាជាខ្មាំង[39] និងត្រូវបានដកហូតសិទ្ធិសេរីភាពជា

---

[36] អនុសញ្ញា CAT, មាត្រា១។ សូមមើល កថាខណ្ឌ២០-២៤ *ខាងក្រោម*។

[37] ដែល អជតក បានតម្កល់យកនៅក្នុងបណ្តឹងសាទុក្ខ។ សូមមើលសំណុំរឿងលេខ០០១-ឯកសារ F28, សាលដីកា ថ្ងៃទី៣ កុម្ភៈ ២០១២, កថាខណ្ឌ២០៩។

[38] សាលក្រមសំណុំរឿង០០១-**E188** សាលក្រមរបស់ ឌុច, កថាខណ្ឌ ២៥៨។ សូមមើលផងដែរ កថាខណ្ឌ ៣៥៩ (រៀបរាប់អំពី "*ស្ថានភាពដែលពោរពេញទៅដោយការភ័យខ្លាចយ៉ាងខ្លាំង*") សូមមើលផងដែរ កថាខណ្ឌ ២៣២ (["វ៉ាន់ ណាត និងដើមបណ្តឹងរដ្ឋប្បវេណី ប៊ូ មេង និង ជុំ ម៉ី] អ្នកទាំងអស់បានរៀបរាប់អំពីលក្ខខណ្ឌដ៏អាក្រក់នៃការចាប់ខ្លួន និងការឃុំខ្លួនរបស់ពួកគេ ការធ្វើបាបខាងផ្លូវរាងកាយ និងផ្លូវចិត្ត ការធ្វើទារុណកម្ម និង *ការភ័យខ្លាចជានិច្ច*")។ សូមមើលបន្ថែម **E3/5799** កាំង ហ្គេកអ៊ាវ *ហៅ* ឌុច, ប្រតិចារឹក ១៥ មិថុនា ២០០៩, ទំព័រ៩១ ("ស: តើលោកទទួលស្គាល់ថា លក្ខខណ្ឌដែលបានដាក់ទៅលើពួកគេនោះ ទោះបីជាលក្ខណៈបុគ្គលក្តី ឬក៏លក្ខណៈរួមគ្នាក្តី ដែលត្រូវបានធ្វើឡើងដើម្បីបំបាក់ចិត្ត បំបាក់ផ្លូវសីលធម៌របស់គេ និងដើម្បីចាត់ទុកថា ពួកគេហ្នឹង ជាសត្វធាតុ ហើយពួកគេត្រូវបានដាក់នៅក្នុងលក្ខណៈមួយ ដែលពួកគេតែងតែមានភាពភ័យខ្លាចជានិច្ចនោះ។ ឆ [...] ខ្ញុំទទួលទាំងអស់ ដោយគោរព អត់ប្រកែកទេ")។

[39] សាលក្រមសំណុំរឿង០០១-**E188** សាលក្រមរបស់ ឌុច, កថាខណ្ឌ២៤៥។ សូមមើលបន្តទៀត ជុំ ម៉ី, សេចក្តីព្រាងប្រតិចារឹក, ១៨ មេសា ២០១៦, ទំព័រ ៤១ ("ពេលនោះ គេនិយាយថា គេនឹងកម្ទេចពួកយើងទាំងអស់ ដែលគេចាត់ទុកថាជាខ្មាំង។"); ទំព័រ៤៥ ("ពេលនោះ គេទុកយើងជាជនក្បត់ជាតិ។"); ឡាច មាន, សេចក្តីព្រាងប្រតិចារឹក, ២៥ មេសា ២០១៦, ទំព័រ៩៧ ("យើងទទួលបានការណែនាំថា អ្នកណាដែលយកមកស-២១ ត្រូវចាត់ទុកថាជាជនក្បត់ជាតិ។ [...] អ្នកដែលយកមកក្នុងគុក ត្រូវបានចាត់ទុកថាជាខ្មាំង")។

មូលដ្ឋានរបស់ខ្លួន[40]។ ដោយសាររាល់អ្នកទោសទាំងអស់ត្រូវបានគេកំណត់សម្លាប់ចោល ដូច្នេះមិនចាំបាច់ប្រព្រឹត្តអំពើមនុស្សធម៌ចំពោះអ្នកជាប់ឃុំទាំងនោះទេ[41]។ ភាពស្ទើតែពិតប្រាកដនៃការស្លាប់នៅមន្ទីរ ស-២១ ធ្វើឱ្យអ្នកទោសគ្មានសង្ឃឹមទាល់តែសោះ[42]។ តាមពិតនោះ ភាពភ័យខ្លាចដែលបង្កើតឡើងតាមរយៈការឃុំខ្លួននៅមន្ទីរ ស-២១ ត្រូវបានបញ្ជាក់យ៉ាងច្បាស់ដោយ ឌុច ៖

> សួរ៖ តើលោកឯកភាពទេថា ជាទូទៅ គឺមានបរិយាកាសភ័យខ្លាច និងសេចក្ដីវន្ទត់ដែលត្រូវដាក់គ្របដណ្ដប់មកលើអ្នកជាប់ឃុំឃាំងទាំងអស់នោះឬ?
> ឆ៖ ប្រាកដណាស់ សូមជម្រាបលោកចៅក្រមដោយស្មោះថា ប្រាកដ[43]។

16. លក្ខខណ្ឌនៃការឃុំឃាំងនៅស-២១ បានបង្កឱ្យមានការឈឺចាប់ផ្លូវកាយ និងផ្លូវចិត្តយ៉ាងធ្ងន់ធ្ងរ និងបានធ្វើអ្នកទោសចុះខ្សោយសម្រាប់ត្រៀមការសួរចម្លើយ។ ពេលមកដល់ស-២១ អ្នកទោស

---

[40] សាលក្រមសំណុំរឿង០០១-E188 សាលក្រមរបស់ ឌុច, កថាខណ្ឌ ២៥៩។ ជុំ ម៉ី, សេចក្ដីព្រាងប្រតិចារឹក, ១៨ មេសា ២០១៦, ទំព័រ៤៥ ("ពេលនោះគេទុកយើងជាជនក្បត់ជាតិ គឺថាគេទុកយើងប្រៀបដូចជាសត្វអ៊ីចឹង១ ទាំងការហូបចុក ទាំងការនិយាយស្ដីស្អី១ គឺថាគេ គឺថាយើងអត់មានសិទ្ធិសេរីភាពអីនិយាយរកគ្នាទេ")។ ឡាច មាន, សេចក្ដីព្រាងប្រតិចារឹក, ២៥ មេសា ២០១៦, ទំព័រ៧១ ("ចំពោះអ្នកទោសដែលឃុំខ្លួនទីនោះ មិនដែលមានមេធាវី ឬអ្នកការពារក្ដី គឺអត់មានទេ គឺអ្នកទោសគឺយកមកចាតែឯង១ ឬមកគ្នាច្រើនអ៊ីចឹង គ្មានមេធាវីណាមកការពារទេ អត់មានទេ")។ អ្នកទោសទាំងអស់នោះត្រូវបាននាំចូលមកដោយក្រុមរបស់ខ្លួ គ្មានការការពារផ្នែកច្បាប់ទេ [...] ក្នុងរបបនោះ អ្នកទោសគ្មានមធ្យោបាយណាការពារខ្លួននោះទេ")។

[41] សាលក្រមសំណុំរឿង០០១-E188 សាលក្រមរបស់ ឌុច, កថាខណ្ឌ ២៥៩។ **E3/5799** កាំង ហ្គេកអ៊ាវ *ហៅ* ឌុច, ប្រតិចារឹក ថ្ងៃទី១៥ មិថុនា ២០០៩, កថាខណ្ឌ៣៥-៣៦ ("អត់មានស្អី [...] ការពារសិទ្ធិគេទេ។ [...] មានន័យថា យើង ខ្ញុំទុកគេជាមនុស្សស្លាប់រួចទៅហើយ។ ឆ្លងពេលសម្រាប់តែយកទោសម្ដាប់ប៉ុន្មនុង។")។ ទំព័រ៨៦-៨៨ ("សូមជម្រាបលោកចៅក្រម! រឿងដែលចាត់មនុស្សដូចជាសត្វ វាមានទិដ្ឋភាពគ្រប់ទាំងអស់ ជាពិសេសពាក្យដែលនិយាយទាក់ទងជាមួយនឹងជនរងគ្រោះ ដែល មកនៅជាប់ទោស។ ក្មេង១ទៅហៅមនុស្សចាស់ អា, អ្អែង។ ដូច្នេះ វាគិតសព្វ១ទៅ វាជារឿងមួយនឹងឡើងដល់រឿងនោះពេលណាវាអាម៉ាស់ខ្លួនឯងពេលនោះ។ ផ្ទាល់ខ្លួនខ្ញុំគិតបានត្រឹមតែចៀស មិនទៅជិត។ ចៀសបានប៉ុនណុង នឹងថាឱ្យមានផែនការលុបបំបាត់ពាក្យគ្រោតគ្រាតបែបនេះមិនបាន ព្រោះតែកាលណាយើងបានធ្វើ គេថាយើងគ្មានទស្សនៈបែងចែកឱ្យច្បាស់រវាងមិត្ត-សត្រូវ។")។។

[42] ញ៉ែម អេន, សេចក្ដីព្រាងប្រតិចារឹក, ២០ មេសា ២០១៦, ទំព័រ ៧៤ ("ពួកគេអស់សង្ឃឹមជាខ្លាំងក្រោយពេលចាប់ខ្លួន និងនាំទៅមណ្ឌល")។ ជុំ ម៉ី, សេចក្ដីព្រាងប្រតិចារឹក, ១៨ មេសា ២០១៦, ទំព័រ ៤៥ ("យើងភ័យណាស់ យើងបារម្ភចេះតែនឹកភ័យ ខ្ញុំមិនដឹងថ្ងៃណានឹងស្លាប់ ទោះបីគេមិនសម្លាប់ឱ្យតែជាប់នៅហ្នឹងយូរ ក៏ត្រូវតែស្លាប់ដែរ")។ **E3/2126** សៀវភៅនិពន្ធដោយ វ៉ាន់ ណាត មានចំណងជើងថា "គំនូរគុកមួយរបស់កម្ពុជា", ទំព័រ ៤២, EN 00396817 ("យើងគ្មានសង្ឃឹមទេ"), ទំព័រ 47, EN 00396822 ("[យើង] គ្មានសង្ឃឹមទេពេលនេះ [...] យើងនឹងជួបវាសនាដូចគ្នានឹងអ្នកនៅទីនេះមុនយើង")។

[43] **E3/5799** កាំង ហ្គេកអ៊ាវ *ហៅ* ឌុច, ប្រតិចារឹក ថ្ងៃទី១៥ មិថុនា ២០០៩, ទំព័រ ៨៩។

ដែលទើបមកដល់ ត្រូវបានគេដាក់ខ្នោះដៃ និងរុំមុខ ហើយខ្លះទៀតត្រូវបានគេរុំបិទមាត់[44]។ មានករណីលើកលែងជាក់លាក់ចំពោះអ្នកទោសសំខាន់ និងអ្នកទោសប្រុសមួយចំនួនដែលអ្នកទោសប្រភេទនេះ ត្រូវបានគេស្រាតសម្លៀកបំពាក់ចេញ ដោយទុកតែខោស្លីប ឬខោខ្លី[45]។ អ្នកទោសត្រូវបានគេដាក់ឲ្យស្ថិតនៅក្រោមការឃាមកាមដោយឆ្មាំប្រដាក់អាវុធ[46] ហើយពេលគេយកចេញពីបន្ទប់ឃុំឃាំងដើម្បីសួរចម្លើយ ពួកគេត្រូវបានគេដាក់ខ្នោះដៃ និងរុំមុខ ដោយធ្វើឲ្យពួកគេវង្វេង និងខ្លាច[47]។ បន្ទប់ឃុំឃាំងនិមួយៗនៅស-២១ មានការខ្វះខាតបង្អួច ឬគ្មានពន្លឺគ្រប់គ្រាន់ខណៈបន្ទប់ឃុំឃាំងរួម គឺជាបន្ទប់ធំដែលមានចំរឹងដែកដាក់ពីលើបង្អួចដើម្បីពង្រឹងវា[48]។ អ្នកទោសធម្មតាត្រូវបានគេដាក់ខ្នោះជើងជាប់នឹងដែករបារវែងនៅក្នុងបន្ទប់ឃុំឃាំងរបស់ពួកគេ[49] ហើយដេកផ្ទាល់នឹងកម្រាល[50]។ មានភស្តុតាងផងដែរស្តីពីអ្នកទោសត្រូវបានគេបង្ខំឲ្យលិតទឹកនោម និងលាមកនៅ

---

[44] ញ៉ែម អេន, សេចក្តីព្រាងប្រតិចារឹក, ២០ មេសា ២០១៦, ទំព័រ៥១ (“មួយរយភាគរយ[នៃអ្នកទោសដែលចូល] នឹងត្រូវបានដាក់ខ្នោះដៃ និងចងមុខ លើកលែងតែស្ត្រី”); ទំព័រ៧៣ (“មានអ្នកខ្លះគេរុំបិទមាត់ ហើយពួកគេទាំងអស់សុទ្ធតែដាក់ខ្នោះដៃ និងរុំមុត”)។ ជុំ ម៉ី, សេចក្តីព្រាងប្រតិចារឹក, ១៨ មេសា ២០១៦, ទំព័រ២២ (“ពេលយើងចុះពីឡានភីកអាប់ (មកដល់ស-២១) យើងត្រូវបានគេដាក់ខ្នោះដៃ និងរុំមុខនឹងក្រមាអ្នកជាប់ឃុំទាំងបីនាក់”)។

[45] សាលក្រមសំណុំរឿង០០១-**E188** សាលក្រមរបស់ ឌុច, កថាខណ្ឌ២៦០។ សូមមើលផងដែរ ឡាច មាន, សេចក្តីព្រាងប្រតិចារឹក, ២៦ មេសា ២០១៦, ទំព័រ៥៧-៥៨ (“អ្នកទោសមកដល់ដែលមានសម្លៀកបំពាក់ជាប់នឹងខ្លួន ត្រូវបានគេបញ្ជាឲ្យដោះចេញ [...] ខ្ញុំមិនដែលឃើញអ្នកទោសណាម្នាក់ពេលមកដល់មានសម្លៀកបំពាក់ទេ។ គេដោះអាវពួកគេមុនគេដឹកពួកគេចូលមក[...]។ ខ្ញុំអាចបញ្ជាក់បានថា គ្មានអ្នកទោសណាម្នាក់មានសម្លៀកបំពាក់ជាប់នឹងខ្លួនទេ”)។

[46] សាលក្រមសំណុំរឿង០០១-**E188** សាលក្រមរបស់ ឌុច, កថាខណ្ឌ២៦០។ សូមមើលបន្ថែម តយ តេង, សេចក្តីព្រាងប្រតិចារឹក, ២១ មេសា ២០១៦, ទំព័រ៨១ (“ពេលយើងកំពុងមានភារកិច្ចយាមកាម គេឲ្យកាំភ្លើងមកយើង។ [...] ឧទាហរណ៍ពេលដល់ភារកិច្ចយាមរបស់ខ្ញុំ គេឲ្យកាំភ្លើងនោះមកខ្ញុំ ហើយខ្ញុំនឹងឲ្យកាំភ្លើងនោះទៅគេវិញពេលខ្ញុំចប់វេណខ្ញុំ”)។

[47] សាលក្រមសំណុំរឿង០០១-**E188** សាលក្រមរបស់ ឌុច, កថាខណ្ឌ២៦៣។ ប្រាក់ ខន, ប្រតិចារឹក, ២៨ មេសា ២០១៦, ទំព័រ១៧-១៨(“ជាទូទៅពួកគេត្រូវគេចងមុខពេលគេយកទៅចូលបន្ទប់សួរចម្លើយ។ គេក៏ដាក់ខ្នោះជើងដែរ។ គេក៏ចងមុខដែរ”)។

[48] សាលក្រមសំណុំរឿង០០១-**E188** សាលក្រមរបស់ ឌុច, កថាខណ្ឌ២៦០។ សូមមើលបន្ថែម ជុំ ម៉ី, សេចក្តីព្រាងប្រតិចារឹក, ១៨ មេសា ២០១៦, ទំព័រ២៣ (“គេប្រើបារដើម្បីបាំងបង្អួច”)។

[49] សាលក្រមសំណុំរឿង០០១-**E188** សាលក្រមរបស់ ឌុច, កថាខណ្ឌ២៦០។ ជុំ ម៉ី, សេចក្តីព្រាងប្រតិចារឹក, ១៨ មេសា ២០១៦, ទំព័រ២៣ (“ខ្ញុំត្រូវគេរុញចូលក្នុងបន្ទប់ រួចហើយប្រាប់ឲ្យអង្គុយ។ បន្ទាប់ពីខ្ញុំបានអង្គុយ គេក៏ដាក់ខ្នោះជើងខ្ញុំ”)។

[50] សាលក្រមសំណុំរឿង០០១-**E188** សាលក្រមរបស់ ឌុច, កថាខណ្ឌ២៦០។ ឡាច មាន, សេចក្តីព្រាងប្រតិចារឹក, ២៥ មេសា ២០១៦, ទំព័រ៧៥ (“អ្នកទោសដេកផ្ទាល់នឹងកម្រាល។ ពួកគេមិនដេកលើកន្ទេលទេ គេមិនឲ្យកន្ទេល ឬខ្នើយទេ”)។

លើកម្រាលនៃបន្ទប់ឃុំឃាំង[51] អ្នកទោសមិនត្រូវបានអនុញ្ញាតឱ្យងូតទឹក[52] និងអ្នកទោសដែលត្រូវបានគេបង្អត់អាហារស្ទើរស្លាប់[53] ផងដែរ។ លក្ខខណ្ឌទាំងអស់នេះបានធ្វើឲ្យជនរងគ្រោះហេវហត់នៅពេលសួរចម្លើយ[54]។

17. នៅទូទាំងនៃការឃុំឃាំងរបស់ពួកគេ អ្នកទោសស-២១ បានរស់នៅក្នុងសេចក្ដីភ័យខ្លាចជាប្រចាំចំពោះការយកទៅសួរចម្លើយ ការវាយដំ ការធ្វើទារុណកម្ម និងការសម្លាប់។ ពួកគេបានឃើញអ្នកជាប់ឃុំដទៃទៀតក្រោយពីត្រឡប់ពីសួរចម្លើយវិញ មានស្នាមជាំ ស្នាមដាច់ការធ្វើកាយវិកលកម្ម និងសញ្ញានៃការវាយដំធ្ងន់ធ្ងរផ្សេងទៀតដែលគេអាចមើលឃើញ[55]។ អ្នកទោសអាចឮសម្លេងថ្ងូរ

---

[51] សាលក្រមសំណុំរឿង០០១-**E188** សាលក្រមរបស់ ឌុច, កថាខណ្ឌ២៧២។ ជុំ ម៉ី, សេចក្ដីព្រាងប្រតិចារឹក, ១៨ មេសា ២០១៦, ទំព័រ២៥, ៣៤ ("គេប្រាប់ឲ្យខ្ញុំបត់ជើងក្នុងបន្ទប់ ហើយបើហៀរដាក់បន្ទប់ គេនឹងឲ្យខ្ញុំឲ្យលិតកន្លែងដែលហៀរនោះ"។ [...] ពេលយើងបត់ជើងតូច ឬបត់ជើងធំក្ដី ប្រសិនបើវាហៀរប្រឡាក់កម្រាល យើងនឹងត្រូវលិតវាពីកម្រាលនោះ...។ លាមកដែលហៀរប្រឡាក់កម្រាល ត្រូវ - ត្រូវប្រើអណ្ដាតរបស់យើងលិតរហូតដល់ជ្រះស្អាត")។

[52] សាលក្រមសំណុំរឿង០០១-**E188** សាលក្រមរបស់ ឌុច, កថាខណ្ឌ២៧០។ ឡាច មាន, សេចក្ដីព្រាងប្រតិចារឹក, ២៥ មេសា ២០១៦, ទំព័រ៧៤ ("ចំពោះអ្នកទោសដែលគេអនុញ្ញាតឲ្យងូតទឹក គេមិនអនុញ្ញាតឲ្យងូតតែម្នាក់ៗឯងទេ។ គេប្រើក្បាលបាញ់ទឹកបាញ់ឲ្យអ្នកទោសទាំងនោះងូតរួមគ្នាតែម្ដង [...]"។ ("ចំពោះអ្នកទោសដែលជាប់ក្នុងបន្ទប់តូច ពួកគេគ្មានឱកាសបានងូតទឹកទេ។ គេមិនឲ្យពួកគេងូតទឹកទេ")។

[53] សាលក្រមសំណុំរឿង០០១-**E188** សាលក្រមរបស់ ឌុច, កថាខណ្ឌ២៦៨-២៦៩។ ជុំ ម៉ី, សេចក្ដីព្រាងប្រតិចារឹក, ១៨ មេសា ២០១៦, ទំព័រ២៦ ("នៅថ្ងៃដែលគេវាយខ្ញុំ និងសួរចម្លើយខ្ញុំ គឺគេឲ្យ - គេឲ្យបបរវារមួយវែងនៅពេលព្រឹក និងនៅល្ងាច ហើយគេឲ្យទឹកខ្ញុំផឹកតែបន្តិចបន្តួចប៉ុណ្ណោះ [...]"។ ទំព័រ៣២ ("ពេលព្រឹក គេឲ្យយើងបបរវារមួយវែក ហើយពេលល្ងាចក៏បបរវារមួយវែកដែរ")។

[54] ជុំ ម៉ី, សេចក្ដីព្រាងប្រតិចារឹក, ១៨ មេសា ២០១៦, ទំព័រ៤៤ ("ស: [...] តើលោកមានពេលសម្រាកនៅចន្លោះពេលសួរចម្លើយទេ? ឆ: ខ្ញុំគ្មានកម្លាំងកំហែងទេដោយសារគ្មានអាហារហូបចុក និងដោយសារគេឲ្យខ្ញុំដេកផ្ទាល់លើកម្រាល អីចឹងហើយបានជាខ្ញុំគ្មានកម្លាំងកំហែង")។

[55] សាលក្រមសំណុំរឿង០០១-**E188** សាលក្រមរបស់ ឌុច, កថាខណ្ឌ២៦៤។ ឡាច មាន, សេចក្ដីព្រាងប្រតិចារឹក, ២៥ មេសា ២០១៦, ទំព័រ៨០ ("ខ្ញុំឃើញឈាម ស្នាមវាយ ស្នាមដាច់រលាត់ និងរបួសនៅលើខ្នង ដៃ និងជើងរបស់អ្នកទោស [...]"។ ពួកគេត្រូវបានគេធ្វើទារុណកម្ម។ ពួកគេត្រូវគេវ៉ៃ។ អីចឹងហើយបានជាពួកគេមានរបួសនៅលើខ្នង ហើយរបួសនឹង -- ស្នាម ហ្នឹង នៅមាន")។ **E3/2126** សៀវភៅនិពន្ធដោយ វ៉ាន់ ណាត មានចំណងជើងថា "គំនូរគុកមួយរបស់កម្ពុជា", ទំព័រ ៤២, EN 00396821 ("ជួនកាល អ្នកទោសខ្លះ ពេលត្រឡប់មកវិញមានរបួស ឬឈាមនៅលើរាងកាយរបស់ពួកគេ ចំណែកខ្លះទៀតបាត់ខ្លួនតែម្ដង")។

និងសម្រែក[56] ហើយនៅក្នុងករណីជាច្រើន អ្នកជាប់ឃុំដែលត្រូវបានគេយកចេញពីបន្ទប់ឃុំឃាំងធម្មតា មិនដែលឃើញវិលត្រឡប់មកវិញទេ[57]។ ដូច្នេះ ការគំរាមកំហែងពិតប្រាកដនៃការធ្វើទារុណកម្មលើរូបរាងកាយ គឺមានលក្ខណៈជ្រួតជ្រាប និងមានជាប្រចាំ។ ការប៉ះទង្គិចពីរបបនេះចំពោះសុខភាពផ្លូវចិត្តរបស់អ្នកទោស គឺពិតជាធ្ងន់ធ្ងរមិនអាចទ្រាំបាន[58] រហូតបានធ្វើឲ្យអ្នកទោសខ្លះប៉ុនប៉ងធ្វើអត្តឃាត[59]។ ដូច្នេះ មន្ទីរសន្តិសុខស-២១ បានអនុវត្តវិធានការនានា ដើម្បីរារាំងអ្នកទោសកុំឲ្យសម្លាប់ខ្លួន នៅមុនពេលចម្លើយសារភាពរបស់ពួកគេមិនទាន់បានទទួល[60]។

---

[56] សាលក្រមសំណុំរឿង០០១-**E188** សាលក្រមរបស់ ឌុច, កថាខណ្ឌ២៦២។ **E3/2126** សៀវភៅនិពន្ធដោយ វ៉ាន់ ណាត មានចំណងជើងថា "គំនូរគុកមួយរបស់កម្ពុជា", ទំព័រ ៥៣, EN 00396828 ("ក្នុងពេលជាមួយគ្នា ខ្ញុំអាចឮសម្រែកនៃការឈឺចាប់ពីគ្រប់ទិសនៃគុក។ ខ្ញុំមានអារម្មណ៍ឈឺចាប់នៅក្នុងខ្លួនរៀងរាល់ពេលខ្ញុំឮសម្រែកម្តងៗ។ [...] ខ្ញុំអាចឮអ្នកយាមស្រែកឲ្យនិយាយការពិត អំពើក្បត់ ឈ្មោះអ្នកចូលដៃ")។ ប្រាក់ ខន, សេចក្តីព្រាងប្រតិចារឹក, ២៨ មេសា ២០១៦, ទំព័រ៥០ (សៈ តើលោកដឹងទេថា តើអាចមានអ្នកទោសនៅស-២១ ស្តាប់ឮសម្លេងរបស់លោក ឬសម្លេងរបស់អ្នកដែលគេសួរចម្លើយដែរឬទេ? ឆៈ ទាក់ទងនឹងសម្លេងឮខ្លាំង សម្លេងខ្លាំងអាចគេឮដែរដោយសារផ្ទះហ្នឹងនៅប្រហែលជា៥០ ឬ៦០ម៉ែត្រពីគុក")។

[57] សាលក្រមសំណុំរឿង០០១-**E188** សាលក្រមរបស់ ឌុច, កថាខណ្ឌ២៦៤។ **E3/2126** សៀវភៅនិពន្ធដោយ វ៉ាន់ ណាត មានចំណងជើងថា "គំនូរគុកមួយរបស់កម្ពុជា", ទំព័រ ៤២, EN 00396821 (ជួនកាល មានអ្នកទោសខ្លះពេលត្រឡប់មកវិញមានរបួស ឬឈាមនៅលើរាងកាយរបស់គេ ចំណែកខ្លះទៀតបាត់ខ្លួន")។ ឡាច មាន, សេចក្តីព្រាងប្រតិចារឹក, ២៥ មេសា ២០១៦, ទំព័រ៦៩ ("អ្នកទោសដែលគេបានដឹកចេញ មិនដែលឃើញវិញត្រឡប់មកវិញទេ។ ពួកគេបាត់ខ្លួនឈឹងតែម្តង")។

[58] ("អត់មានស្អី [...] ការពារសិទ្ធិគេទេ។ [...] មានន័យថា យើងខ្ញុំទុកគេជាមនុស្សស្លាប់រួចទៅហើយ។ ឆ្លងពេលសម្រាប់តែយកទៅសម្លាប់ប៉ុននុង។")។ ទំព័រ៨៦-៨៨ ("សូមជម្រាបលោកចៅក្រម! រឿងដែលចាត់មនុស្សដូចជាសត្វ វាមានទិដ្ឋភាពគ្រប់ទាំងអស់ ជាពិសេសពាក្យដែលនិយាយទាក់ទងជាមួយនឹងជនរងគ្រោះ ដែលមកនៅជាប់ទោស។ ក្មេងៗទៅហៅ មនុស្សចាស់ អា, អ្អែង។ ដូច្នេះ វាគិតសព្វៗទៅ វាជារឿងមួយនឹងឡើងដល់រឿងនោះពេលណា វាអាម៉ាស់ខ្លួនឯងពេលនោះ។ ផ្ទាល់ខ្លួនខ្ញុំគិតបានត្រឹមតែចៀស មិនទៅជិត។ ចៀសបានប៉ុនណុង នឹងថាឲ្យមានផែនការលុបបំបាត់ពាក្យគ្រោតគ្រាតបែបនេះមិនហ៊ាន ព្រោះតែកាលណាយើងហ៊ានធ្វើ គេថាយើងគ្មានទស្សនៈបែងចែកឲ្យច្បាស់រវាងមិត្ត-សត្រូវ។")។

[59] ជុំ ម៉ី, សេចក្តីព្រាងប្រតិចារឹក, ១៨ មេសា ២០១៦, ទំព័រ៦៤ ("ខ្ញុំចាត់ទុកខ្លួនឯងជាមនុស្សឆ្កួតជាជាង ហើយមានពេលខ្លះ ខ្ញុំបានចំណាយពេល - ខ្ញុំចំណាយពេលឃំ")។

[60] សាលក្រមសំណុំរឿង០០១-**E188** សាលក្រមរបស់ ឌុច, កថាខណ្ឌ២៦៥។ ឡាច មាន, សេចក្តីព្រាងប្រតិចារឹក, ២៥ មេសា ២០១៦, កថាខណ្ឌ៧៩-៨០ (ជាបញ្ជាពីមេដឹកនាំនៅមណ្ឌលដែលយើងត្រូវតាមដានអ្នកទោសជាប្រចាំ និងធានាថាអ្នកទោសមិនបំបាក់ខ្មោះ ឬព្យាយាមសម្លាប់ខ្លួនដោយចងកបានឡើយ។ ទាំងនេះគឺជាតួនាទីរបស់អ្នកយាម។ [...] អ្នកទោសអាចព្យាយាមសម្លាប់ខ្លួនដោយសារគេអស់សង្ឃឹម ឬខ្លាច ចឹចឹងហើយបានជាគេអាចសម្លាប់ខ្លួន។ ពួកគេគិតថា គេអាចនឹងត្រូវគេយកទៅសួរចម្លើយ និងធ្វើទារុណកម្ម។ នោះហើយអាចជាកង្វល់ចំបងរបស់ពួកគេដែលគេអាចនឹងយកពួកគេទៅសួរចម្លើយ និងធ្វើទារុណកម្ម។ [...] ការណែនាំពីថ្នាក់ដឹកនាំគឺថា ធ្លាប់មានអ្នកទោសព្យាយាមសម្លាប់ខ្លួន ហើយអ្នកទោសចាប់យកកម្លាំងពីអ្នកយាម រួចហើយបាញ់សម្លាប់ខ្លួនឯងតែម្តង។ ដូច្នេះ មានការណែនាំពីថ្នាក់លើឲ្យមានការប្រុងប្រយ័ត្នចំពោះបញ្ហានេះ។ ហើយ

18. នៅក្នុងអំឡុងនៃការសួរចម្លើយ ទោះបីជាការធ្វើទារុណកម្មលើរូបរាងកាយដោយផ្ទាល់មិនត្រូវបានគេអនុវត្តក៏ដោយ ក៏អ្នកសួរចម្លើយបានប្រើវិធីសាស្ត្រផ្សេងស្មើនឹងការធ្វើទារុណកម្មផ្លូវចិត្តទៅលើអ្នកទោស "ដើម្បីបំបែកការតស៊ូរបស់ពួកគេ និងធ្វើឲ្យពួកគេភ័យខ្លាចជាប្រចាំ" ដើម្បីទាញយកចម្លើយសារភាព[61]។ ការគំរាមកំហែងធ្វើទារុណកម្មផ្លូវកាយបានបង្ហាញជានិច្ចនៅក្នុងពេលសួរចម្លើយ ដោយអ្នកសួរចម្លើយតាំងបង្ហាញឲ្យឃើញនូវឧបករណ៍ធ្វើទារុណកម្មដូចជា អង្គំ ដំបង កាំបិត និងពូថៅ ដើម្បីធ្វើឲ្យអ្នកជាប់ឃុំស្លុតរន្ធត់[62]។ បើសិនអ្នកទោសណាម្នាក់មិនបាន "ឆ្លើយសារភាព" ឲ្យបានគ្រប់គ្រាន់អំពីអំពើក្បត់របស់ខ្លួននៅក្នុងពេលសួរចម្លើយទេ នោះគាត់នឹងត្រូវគេធ្វើទារុណកម្មផ្លូវកាយ ឬត្រូវបានគេគំរាមកំហែងធ្វើទារុណកម្ម[63]។ មានអ្នកជាប់ឃុំឃាំងខ្លះអាចបានសារភាពដើម្បី *បញ្ចៀស* ការធ្វើទារុណកម្មផ្លូវកាយក្នុងពេលសួរចម្លយ តែនេះក៏មិនបានធ្វើឲ្យចម្លើយសារភាពរបស់ពួកគេ មិនមែនជាផលិតផលដែលកើតចេញពីការធ្វើទារុណកម្មនោះឡើយ។

---

ព័ត៌មាននេះត្រូវបានគេបញ្ជូនមកយើងនៅក្នុងអង្គភាពការពារ")។ ឡាច មាន, សេចក្ដីព្រាងប្រតិចារឹក, ២៦ មេសា ២០១៦, ទំព័រ ៥៧ ("យើងខ្លាចអ្នកទោសប្រើខោអាវរបស់ខ្លួនចងកសម្លាប់ខ្លួនឯង")។

[61] សាលក្រមសំណុំរឿង០០១-**E188** សាលក្រមរបស់ ឌុច, កថាខណ្ឌ២៤៥។

[62] សាលក្រមសំណុំរឿង០០១-**E188** សាលក្រមរបស់ ឌុច, កថាខណ្ឌ២៤៥។ **E3/5800** កាំង ហ្គេកអ៊ាវ *ហៅ* ឌុច, ប្រតិចារឹក ១៦ មិថុនា ២០០៩, ទំព័រ២២, EN 00341979, KH 00342769 ("[...] [ស] ដំបង ឬក៏ខ្សែ ប្រដាប់ឆក់ខ្សែភ្លើងះអីជាដើម [...] នៅក្នុងគុ [...] យើងបានចាត់ចែងរៀបចំជាមុនទេ នូវឧបករណ៍សម្រាប់ធ្វើទារុណកម្មទាំងនោះ ដើម្បីជាមធ្យោបាយមួយបន្លាច ដល់អ្នកដែលត្រូវចម្លើយ? ឆ. [...] ពួកអ្នកសួរខ្លះ គេថា អ្ហែ! ដាក់គ្រាន់តែបន្លាចទេ។ ដូច្នេះ ប្រដាប់ដែលត្រៀម ខ្ញុំជឿថាមានគ្រប់គ្នាគឺដំបង ឬរំពាត់សម្រាប់ធ្វើទារុណកម្ម។ ឯចំណែកអាទូរស័ព្ទប្អូនជ្រុងសម្រាប់រវៃឆក់ខ្សែភ្លើងក៏អាចមានគ្រប់គ្នាដែរ។ [...] ដោយឡែក ប្រដាប់ខ្លះសម្រាប់កំញើញ ដូចជាដាវធំ ប្រថៅធំអីហ្នឹង គ្រាន់តែកំញើញទេ ហ្នឹងមាន")។

[63] ឡាច មាន, ពង្រាងប្រតិចារឹក, ២៦ មេសា ២០១៦, ទំព័រ៧០ ("នេះជាគោលការណ៍នៃការសួរចម្លើយដើម្បីឲ្យពិតប្រាកដហើយត្រឹមត្រូវ មានការណែនាំ និង សម្លុតអ្នកទោស សម្លុតខ្លះ ហើយណែនាំខ្លះទៅឲ្យអ្នកទោសហ្នឹងសារភាព ហើយឲ្យនិយាយត្រឹមត្រូវ")។ ឡាច មាន, ពង្រាងប្រតិចារឹក, ២៥ មេសា ២០១៦, ទំព័រ ៩៧-៩៨ ("គេឲ្យយើងសួរចម្លើយឲ្យចេញឲ្យអ្នកទោសហ្នឹងសារភាពមកថា ជាក្បត់ជាតិនេះហើយ។ ពីព្រោះគេកំណត់ថាអ្នកដែលចូលមកក្នុងហ្នឹងគឺ សុទ្ធតែជាខ្មាំងក្បត់ជាតិហើយបានគរចាប់មក។ [...] ចំពោះអ្នកទោសដែលសួរចម្លើយហើយមិនបានឆ្លើយ គឺអ្នកទោសនោះគឺអាចធ្វើទារុណកម្ម")។ **E3/7543** បទសម្ភាសន៍របស់ DC-Cam ជាមួយ គុប រី, ៩ តុលា ២០០៣, EN 00184169 ("គាត់មិនត្រូវបានវាយទេ នៅលើកទីមួយ, ក៏ប៉ុន្តែលើកទីពីរ [...] គាត់ត្រូវបានវាយដោយសារផ្ដល់ចម្លើយមិនត្រឹមត្រូវ")។ **E3/5800** កាំង ហ្គេកអ៊ាវ *ហៅ* ឌុច, ប្រតិចារឹក, ១៦ មិថុនា ២០០៩, ទំព័រ២៧, EN 00341984, KH 00342773 ("ចំនួនដែលត្រូវសួរនេះច្រើនលើក ឬតិចលើក យូរឆាប់ប៉ុនណា វាអាស្រ័យលើសេចក្ដីសារភាពរបស់គេ។ ទីមួយ បើសេចក្ដីសារភាពនេះផ្ទាល់ខ្ញុំបាទមើលទៅសមរម្យគ្រប់គ្រាន់ហើយ ក៏បញ្ចប់ការសួរចម្លើយនោះទៅ។ ក៏ប៉ុន្តែ មនុស្សខ្លះដែលមានសារៈសំខាន់ខ្លាំង [...], សួរចម្លើយដល់ទៅប្រាំលើក បើតាមខ្ញុំចាំ។ [...] ដូច្នេះ វាះអាស្រ័យនឹងគេឆ្លើយពេញចិត្តយើង ពេញចិត្តខាងលើ ឬមិនពេញចិត្ត")។

អ្នកសួរចម្លើយបានប្រើប្រាស់ការគំរាមកំហែងប្រឆាំងគ្រួសារជនរងគ្រោះ ដើម្បីបំភ័យពួកគេ[64]។ ដោយសារចំនួនគ្រួសាររបស់អ្នកជាប់ឃុំត្រូវបានគេបញ្ជូនទៅស-២១ ជាទីកន្លែងដែលពួកគេត្រូវបានគេធ្វើទារុណកម្ម និងសម្លាប់ចោលផងដែរនោះ[65] ការគំរាមកំហែងនេះ គឺអាចជឿជាក់បាន និងមានឥទ្ធិពល។ អ្នកសួរចម្លើយក៏ប្រើវិធីបំភ័យផ្សេងទៀតចំពោះអ្នកជាប់ឃុំផងដែរ[66] និងបានប្រព្រឹត្តចំពោះពួកគេដោយការប្រមាថ[67] បណ្តាលឲ្យពួកគេទទួលរងនូវភាពអាមាស់ហួសហេតុ[68]។

19. ចម្លើយសារភាពដែលទទួលបានពីមន្ទីរ ស-២១ គឺពិតជាលទ្ធផលនៃការឈឺចាប់ និងការរងទុក្ខផ្លូវកាយ និងផ្លូវចិត្តធ្ងន់ធ្ងរ ថាតើវិធីធ្វើទារុណកម្មផ្លូវកាយត្រូវបានដាក់ឲ្យអនុវត្ត នៅក្នុងបន្ទប់សួរចម្លើយ ឬក៏អត់នោះ។ ភ័ស្តុតាងដែលបានមកក្នុងកាលៈទេសៈនានាដូចជាកាលៈទេសៈទាំងនេះ គឺ *ពិតជា* អ្វីដែល CAT បានស្វែងរកមិនដាក់បញ្ចូល នៅពេលវាបានហាមឃាត់ការធ្វើទារុណកម្មផ្លូវកាយ និងផ្លូវចិត្តផងដែរនោះ។

*កុយ ធួន*

---

[64] សាលក្រមសំណុំរឿង០០១-**E188** សាលក្រមរបស់ ឌុច, កថាខណ្ឌ២៤៥។ **E3/5802** កាំង ហ្គេកអ៊ាវ *ហៅ* ឌុច, ប្រតិចារឹក, ២២ មិថុនា ២០០៩, ទំព័រ ៣៦-៣៧ ("ខាងលើណែនាំឲ្យខ្ញុំ [...] ប្រាប់ បងយ៉ា ថា ខាងលើឃាត់ខ្លួនប្រពន្ធគាត់ និងកូនគាត់។ ... ស. តើនេះជាការគំរាមកំហែង ដើម្បីឲ្យយ៉ា សារភាពបន្ថែមអំពីសកម្មភាពក្បត់ដែ ឬទេ? ឆ. ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា គឺវាពិតជាអ៊ីចឹងមែន")។ **E3/834** សៀវភៅកំណត់ដៃរបស់ ប៉ុន/ទុយ, ១២ មេសា ១៩៧៨ - ១៧ ធ្នូ ១៩៧៨, ទំព័រ២៩ EN 00184511, KH 00077523 ("ត្រូវខំគិតពីរឿងមជ្ឈដ្ឋានគ្រួសារ")។

[65] ញ៉ែម អេន, សេចក្តីព្រងប្រតិចារឹក, ២០ មេសា ២០១៦, ទំព័រ ៦៤ ("ខ្ញុំបានឃើញក្មេងៗត្រូវបានគេដឹកចូលទៅក្នុងមន្ទីរតាមឡាន ហើយទាំមូល -- ពេលខ្លះទាំងអស់នេះត្រូវបាននាំចូលមកជាមួយនឹងគ្រួសារទាំងមូលតែម្តង")។ **E3/5799** កាំង ហ្គេកអ៊ាវ ហៅ ឌុច, ប្រតិចារឹក ថ្ងៃទី ១៥ មិថុនា ២០០៩, ទំព័រ ៦២ ("ភាគច្រើនស្ត្រីទាំងអស់នេះដែលជាប់នៅ ស-២១ ជាប់មកដោយសារប្តី។ [...] ហើយស្ត្រីផ្សេងទៀត ជាប់មកក្នុងឋានៈជាកូនរបស់គេ")។ **E3/5154** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហ៊ឹម ហ៊ុយ, EN 00161603; KH 00146651 ("CB: ម្តាយត្រូវគេសម្លាប់ តើកូនធ្វើដូចម្តេច? HH: [..] ប៉េងយកទីសម្លាប់ចោលនៅក្នុងបរិវេនគុកទួលស្លែងតែម្តង")។

[66] សាលក្រមសំណុំរឿង០០១-**E188** សាលក្រមរបស់ ឌុច, កថាខណ្ឌ ២៤៥។ **E3/834** សៀវភៅកំណត់ដៃរបស់ ប៉ុន/ទុយ, ១២ មេសា ១៩៧៨ – ១៧ ធ្នូ ១៩៧៨, ទំព័រ២៩, EN 00184511, KH 00077524 ("ត្រូវតែរកចំណុចខ្សោយឲ្យឃើញ")។

[67] សាលក្រមសំណុំរឿង០០១-**E188** សាលក្រមរបស់ ឌុច, កថាខណ្ឌ ២៤៥។ **E3/5800** កាំង ហ្គេកអ៊ាវ ហៅ ឌុច, ប្រតិចារឹក ថ្ងៃទី ១៦ មិថុនា ២០០៩, ទំព័រ ៨៨, EN 00342045, KH 00342820។

[68] ជុំ ម៉ី, សេចក្តីព្រាងប្រតិចារឹក, ១៨ មេសា ២០១៦, ទំព័រ ៤៧ ("[អ្នកសួរចម្លើយ] អង្គុយលើក្បាលខ្ញុំ [...] ជម្រាបលោកព្រះរាជអាជ្ញា គេប្រកាន់ណាស់ រឿងក្បាលហ្នឹង គេប្រកាន់ណាស់ ខ្មែរយើងមិនឲ្យពីណាអង្គុយលើក្បាលអីចឹងទេ។")

20. សេចក្តីអះអាងរបស់ នួន ជា ដែលថា "មានភស្តុតាងដែលគួរឱ្យជឿជាក់បានដែលបង្ហាញថា នៅក្នុងករណី កុយ ធួន ចម្លើយសារភាពនៅមន្ទីរ ស-២១ របស់គាត់ មិនត្រូវបានធ្វើឡើងដោយទារុណកម្មឡើយ"[69] មើលរំលងទាំងស្រុងនូវការពិតនៃការឃុំឃាំង និងការសួរចម្លើយ កុយ ធួន នៅស-២១។ មិនមានភស្តុតាងណាមួយបានលើកឡើងដោយ នួន ជា បដិសេធអង្គហេតុដែលថាមាន "ហានិភ័យពិតប្រាកដ" ដែលចម្លើយសារភាពនានារបស់ កុយ ធួន ត្រូវបានចំរាញ់យកតាមរយៈការធ្វើទារុណកម្មឡើយ។

21. សូម្បីតែនៅក្នុងអវត្តមាននៃទារុណកម្មខាងផ្លូវកាយដែលអះអាង វាច្បាស់លាស់ដែលថា កាលៈទេសៈ ដែល កុយ ធួន បានដឹងខ្លួនថាគាត់បានចូលទៅក្នុង ស-២១ នៅខែមករា ឆ្នាំ១៩៧៧[70] និងត្រូវបានសួរចម្លើយដោយ ឌុច បង្កើតបានជាទារុណកម្ម*ផ្លូវចិត្ត*។ នៅពេលដែល កុយ ធួន បានមកដល់ ស-២១ គាត់ត្រូវបានឃុំខ្លួននៅក្នុងផ្ទះអស់រយៈពេលប្រាំបីខែ ឬប្រាំបួនខែ រួចហើយ[71]។ ក្នុងឋានៈជាមន្ត្រី បកក ជាន់ខ្ពស់បំផុតក្នុងចំណោមមន្ត្រីជាន់ខ្ពស់នានា គាត់មិនអាចខកខានមិនបានដឹងថា ស-២១ ជាមន្ទីរមួយ សម្រាប់ធ្វើទារុណកម្ម និងការស្លាប់ពិតប្រាកដ សម្រាប់ខ្លួនគាត់ និងទំនងជាពិតលើក្រុមគ្រួសាររបស់គាត់[72]។ នៅពេលនោះ គាត់ត្រូវបានដាក់ខ្នោះជើង[73] ដកហូត

---

[69] **E399** សំណើរបស់ នួនជា, កថាខណ្ឌ១៨។

[70] **E3/355** កំណត់ហេតុនៃការសួរចម្លើយ ឌុច ចុះថ្ងៃទី ១៩ វិច្ឆិកា ២០០៨, ៩ វិច្ឆិកា ២០០៨, ទំព័រ៣, EN 00242874, KH 00239832។ សូមអានផងដែរ កំណត់សម្គាល់ជើងទំព័រលេខ ៧១ *យោងខាងក្រោម*។

[71] សូមអាន **E3/16** ខៀវ សំផន, "ពិចារណាអំពីប្រវត្តិសាស្ត្រកម្ពុជាពីដើមរហូតដល់សម័យកម្ពុជាប្រជាធិបតេយ្យ", EN 00498271-73 (ដោយបានថ្លែងថា កុយ ធួន ត្រូវបានដាក់ "ឃុំនៅក្នុងផ្ទះមួយ នៅក្រោមការឃ្លាំមើលរបស់គណៈអចិន្ត្រៃយ៍" ពីខែមេសា ឆ្នាំ១៩៧៦ រហូតដល់ ខែមករា ឆ្នាំ១៩៧៧។ នៅខែមករា ឆ្នាំ១៩៧៧ "គណៈអចិន្ត្រៃយ៍បញ្ជូនគាត់ទៅកាន់ ស-២១ ដើម្បីសួរចម្លើយ")។ **E3/355** កំណត់ហេតុនៃការសួរចម្លើយ ឌុច ចុះថ្ងៃទី ១៩ វិច្ឆិកា ២០០៨, ៩ វិច្ឆិកា ២០០៨, ទំព័រ៣, EN 00242874, 00242878, KH 00239832, KH 00239836 (ដោយបានថ្លែងថា កុយ ធួន ត្រូវបានឃុំខ្លួននៅក្នុងផ្ទះអស់រយៈពេលប្រហែល ៨ ខែ)។ **E3/5810** កាំង ហ្កេកអ៊ាវ *ហៅ* ឌុច, ប្រតិចារឹក, ២៥ វិច្ឆិកា ២០០៩, ទំព័រ៥២, EN 00406696 (ដោយបានថ្លែងថា កុយ ធួន ត្រូវបានដាក់នៅក្នុងផ្ទះមួយ ពីថ្ងៃទី៨ ខែមេសា ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅកាន់ ស-២១ នៅថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៧៧)។

[72] តាមពិត នៅក្នុងករណីរបស់ កុយ ធួន ការគំរាមកំហែងនេះគឺត្រូវបានធ្វើឱ្យសម្រេច។ ឌុច ទទួលស្គាល់ថា ប្រពន្ធរបស់ កុយ ធួន គឺ យ៉ុន Yon ត្រូវបានចាប់ខ្លួន និងបញ្ជូនទៅកាន់ ស-២១ ដោយសារលទ្ធផលផ្ទាល់នៃការចាប់ខ្លួនរបស់គាត់។ សូមអាន **E3/5799** កាំង ហ្កេកអ៊ាវ *ហៅ* ឌុច, ប្រិចារឹក ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩,ទំព័រ៦២ ("ស្ត្រីទាំងនេះដែលជាប់នៅ ស-២១ ជាប់មកដោយសារប្តី។ ប្រពន្ធរបស់ កុយ ធួន សុទ្ធតែក្នុងនាមជាប្រពន្ធគេ។ បន្ទាប់មក នាងត្រូវបានសម្លាប់ នៅ ស-២១។ សូមអាន **E3/342** បញ្ជីឈ្មោះអ្នកទោសនៅ ស-២១ ពិនិត្យឡើងវិញ, លេខរៀង ១២១៤៩។

ឱកាសរបស់គាត់ក្នុងការប្ដឹងរឿងរបស់គាត់ទៅ *អង្គការ* ដោយផ្ទាល់[74] ហើយត្រូវបានសួរចម្លើយផ្ទាល់ដោយប្រធាន ស-២១។ រឿងរ៉ាវដ៏គួឱ្យភ័យខ្លាចរបស់ ឌុច ស្ដីពីលក្ខណ្ឌបំភិតបំភ័យ ដែលគាត់បានទាញយកព័ត៌មានពី កុយ ធួន ដោយការប្រើប្រាស់នូវអ្វីដែលគេហៅថា "វិធីសាស្ត្រត្រជាក់"[75] នៃការសួរចម្លើយ "ដោយពុំមានទារុណកម្ម" បង្ហាញពីការបង្ខិតបង្ខំផ្លូវចិត្តដ៏ខ្លាំងក្លាបំផុត ដើម្បីទទួលបានចម្លើយសារភាពដំបូងរបស់ កុយ ធួន។ ឌុច បានគំរាម កុយ ធួន ដោយការធ្វើបាបផ្លូវកាយ បើសិនជាគាត់មិនព្រមសារភាព[76] ទៅតាមការរំពឹងទុករបស់បក្ស[77] និងដោយការ

---

[73] **E3/347** បទសម្ភាសន៍របស់ កាំង ហ្កេកអ៊ាវ *ហៅ* ឌុច ដោយ UNHCR, ៤-៦ ឧសភា ១៩៩៩ ("បទសម្ភាសន៍របស់ ឌុច"), ទំព័រ១៣, EN 00185008, KH 00160897 ("ខ្ញុំយកគាត់ទៅដាក់ ក្នុងគុកពិសេសមួយ ដែលបានរៀបចំហើយជាស្រេច។ ខ្ញុំឱ្យគាត់ដេកលើគ្រែផ្ដៅមួយ ហើយដាក់ខ្នោះជើងគាត់")។ **E3/5799** កាំង ហ្កេកអ៊ាវ *ហៅ* ឌុច, ប្រិចារឹក ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩,ទំព័រ៤៥ ("ខ្ញុំឃើញផ្ទាល់នឹងភ្នែក។ រូបថតដែលនៅសល់នេះ បញ្ចាំងឱ្យឃើញ កុយ ធួន ជាប់ខ្នោះជើងភ្ជាប់ទៅនឹងគ្រែផ្ដៅមួយ ដែលគាត់សម្រាន្តនៅនុង នេះពិត")។

[74] **E3/347** ចម្លើយរបស់ ឌុច ខែឧសភា ១៩៩៩, ទំព័រ១៣, EN 00185008, KH 00160896 ("'សមមិត្តមិនបាច់សួរខ្ញុំទេ ចាំជួបអង្គការ ចាំខ្ញុំរាយការណ៍ (ប៉ុល ពត)។ ចំពោះមុខសភាពការណ៍បែបនេះ យើងជាកម្មាភិបាលសួរចម្លើយ យើងប្រកាន់អាកប្បកិរិយាយ៉ាងម៉េច។ ខ្ញុំសើចបន្តិចញឹមៗ ហើយខ្ញុំថា ដល់ថ្នាក់ប៉ុណ្ណេះទៅហើយ បងកុំសង្ឃឹមបានជួបអង្គការ រាយការណ៍ជូនអង្គការ មានតែរាយការណ៍ជូនអង្គការតាមរយៈខ្ញុំទេ។ ខ្ញុំនិយាយប៉ុណ្ណឹងក៏ឱ្យគេនាំគាត់ទៅកងបាត់ទៅ។")។

[75] សូមមើល **E3/1570** កំណត់ហេតុនៃការសួរចម្លើយ ឌុច, EN 00154194, KH 00154224 ("*វិធីសាស្ត្រត្រជាក់* គឺជាវិធីដែលមិនមានការប្រើទារុណកម្ម និងការជេស្ដីទេ ប៉ុន្តែ ជាការប្រើការបញ្ចុះបញ្ចូលឃោសនា។ ឧទាហរណ៍ ពេលខ្ញុំសួរ កុយ ធួន ...")។

[76] **E3/347** ចម្លើយរបស់ ឌុច ខែឧសភា ១៩៩៩, ទំព័រ១៤, EN 00185009, KH 00160897 ("ខ្ញុំញញឹមដាក់គាត់ ដល់ខ្ញុំញញឹមដាក់គាត់ ខ្ញុំក៏ចាប់ផ្ដើមនិយាយ ថាគាត់លេងល្បិចឱ្យខ្ញុំវ៉ៃឱ្យគាត់ឆ្លើយ គ្នាផ្លូវទេគេស្គាល់ល្បិចនេះហើយ។ ខ្ញុំនិយាយជាមួយគាត់ច្រើន តែចំណុចសំខាន់តែរឿងហ្នឹងទេ។ ហើយឱ្យគាត់សរសេរម្ដងទៀត។ គាត់ប្រតិកម្មទៀត - គាត់សរសេរម្ដងទៀត បានបន្ទាន់ទេគាត់ប្រតិកម្មម្ដងទៀត [...] ពេលនោះខ្ញុំឱ្យប៊ុនទៅម្ដង ប្រហែលជាមួយម៉ោងក្រោយមក ខ្ញុំឱ្យ ប៊ុន ទៅ ហើយខ្ញុំហាមគាត់ដាច់ខាតកុំធ្វើអីគាត់ឱ្យសោះ តែវ៉ៃ ខាងសំដីឱ្យឈ្នះ មានប្រៀបជាងគាត់។ ដល់រួចមួយសន្ទុះ គាត់ក៏ចាប់ផ្ដើមសរសេរម្ដងទៀត")។

[77] **E3/347** ចម្លើយរបស់ ឌុច ខែឧសភា ១៩៩៩, ទំព័រ១៤, EN 00185009, KH 00160897 ("ពេលនោះ សុន សេន ទូរសព្ទមកផ្ទះខ្ញុំ។ ខ្ញុំជម្រាបលោកគ្រូ សុន សេន ថា បានហើយបង អត់បាច់វ៉ៃទេ តែខ្ញុំត្រូវមាត់គេ (មិនស៊ីគ្នា)។ គាតថាឯងថតចម្លងទៅហើយអញឱ្យគេទៅយកឥឡូវ។ នេះជាសេចក្ដីរាយការណ៍ជាដំបូងដល់លោកគ្រូ សុន សេន បានសេចក្ដីសារភាពឱ្យគាត់អាន។ គាត់ថាឱ្យវាសរសេរតទៅទៀត (តាមទូរសព្ទ) ឱ្យសរសេរឱ្យបានច្បាស់និងពិស្ដារ។"); ទំព័រ២៩, EN 00185024, KH 00160904 ("ស៖ នៅក្នុងករណីណាដែលប្រើធីមក្ដៅ? ឆ៖ នៅពេលណាដែលវាអត់ឆ្លើយ ឬក៏ឆ្លើយទៅវាមិនពេញចិត្តនោះណា។")។ សូមមើលផងដែរ **E3/5800** កាំង ហ្កេកងអ៊ាវ *ហៅ* ឌុច, ប្រតិចារឹក, ១៦ មិថុនា ២០០៩, ទំព័រ២៧, EN 00341984 ("ចំនួនដែលត្រូវសួរនេះ ច្រើនលើក ឬតិចលើក យូរឆាប់ប៉ុនណា វាស្រ័យលើសេចក្ដីសារភាពរបស់គេ។ ទីមួយ បើសេចក្ដីសារភាពនេះផ្ទាល់ខ្ញុំបានមើលទៅសមរម្យគ្រប់គ្រាន់ហើយ ក៏បញ្ចប់ការសួរចម្លើយនោះទៅ។ ក៏ប៉ុន្តែ មនុស្សខ្លះដែលមាន

ដាក់ទណ្ឌកម្មគាត់ចំពោះ "ការប្រតិកម្ម"[78]។ តាមពិតទៅ កង្វល់ដដែលៗរបស់ ឌុច ដែលថា កុយ ធួន អាចនឹងសម្លាប់ខ្លួនឯង បង្ហាញថា គាត់បានដឹងអំពីសភាពតានតឹងផ្លូវចិត្តដ៏ខ្លាំងក្លាបំផុតរបស់ កុយ ធួន បន្ទាប់ពីគាត់បានមកដល់ ស-២១[79]។

22. បន្ថែមលើនេះទៀត ចម្លើយសារភាពដែលមានដែល នួន ជា ស្នើសុំប្រើប្រាស់ក្នុងសំណុំរឿង០០២/០២នោះ[80] ស្ទើតែទាំងអស់មិនមែនជាចម្លើយដែលត្រូវបានធ្វើឡើងដោយ ឌុច នោះទេ។ ឌុច បានផ្តល់កស្តីកម្មថា ចម្លើយសារភាពដំបូងចំនួនពីររបស់ កុយ ធួន ត្រូវបានធ្វើឡើងនៅថ្ងៃទី២៩ ខែមករា ឆ្នាំ១៩៧៧[81]។ បន្ទាប់ពីនោះមក ការសួរចម្លើយ កុយ ធួន ដែលនៅសល់ត្រូវបានចាត់តាំងឲ្យ ប៉ុន ដែលជាអ្នកសួរចម្លើយនៅ ស-២១[82]។ កាលបរិច្ឆេទចម្លើយសារភាពជាភ័ស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះ គឺខែកុម្ភៈ មីនា និងមេសា ឆ្នាំ១៩៧៧ ចម្លើយមុនដំបូងបង្អស់ គឺនៅថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ១៩៧៧[83]។ ចម្លើយរបស់ ឌុច ដែលថារូបគាត់មិនបានធ្វើទារុណកម្ម កុយ ធួន ដោយ

សារៈសំខាន់ខ្លាំងពេក ដូចជា កុយ ធួន អ៊ីចឹង។ សួរចម្លើយដល់ទៅប្រាំលើក។ [...] ដូច្នេះវាអាស្រ័យនឹងគេឆ្លើយពេញចិត្តយើង ពេញចិត្តខាងលើ ឬមិនពេញចិត្ត វាអាស្រ័យទៅលើចម្លើយសារភាពនោះ។

[78] **E3/347** ចម្លើយរបស់ ឌុច ខែឧសភា ១៩៩៩, ទំព័រ ១៤, EN 00185009, KH 00160897 ("នៅពេលនេះ ខ្ញុំឲ្យគេគត់គាត់មួយដៃពីរឿងគាត់ ប្រតិកម្ម (ឱ ប៉ុន)។ (ខ្ញុំឲ្យប៉ុនទៅ ខ្ញុំប្រាប់ឲ្យ ប៉ុន គក់គាត់មួយដៃដើម្បីឲ្យគាត់ឈប់ប្រតិកម្ម។)")

[79] **E3/347** ចម្លើយរបស់ ឌុច ខែឧសភា ១៩៩៩, ទំព័រ ១៣, EN 00185008, KH 00160897 ("ខ្ញុំឲ្យកងពិសេសខ្ញុំទៅយាមគាត់ខ្លាចគាត់សម្លាប់ខ្លួន"); ទំព័រ១៤, EN 00185009, KH 00160897 ("ខ្ញុំចាត់វិធានការណ៍ដូចតទៅ៖ ទី១ ការពារធ្វើម៉េចកុំឲ្យគាត់សម្លាប់ខ្លួនបាន")។

[80] **E399** សំណើរបស់ នួន ជា,ជើងទំព័រ ២១ *យោងសំអាង* **E3/1604** ចម្លើយសារភាពមន្ទីរ ស-២១ របស់ កុយ ធួន។ **E3/1753** ចម្លើយសារភាពរបស់ កុយ ធួន អំពីគណៈកម្មាធិការប្រឆាំងបដិវត្តនៅសៀមរាប និងឧត្តរមានជ័យ។ **E3/3856** ចម្លើយសារភាពរបស់ កុយ ធួន ហៅ ឃួន។

[81] **E3/5810** កាំង ហ្កេកអ៊ាវ *ហៅ* ឌុច, ប្រតិចារឹក, ២៥ វិច្ឆិកា ២០០៩, ទំព័រ៥២, EN 00406696; **E3/451** កំណត់ហេតុសួរចម្លើយ ឌុច ថ្ងៃទី៥ ឧសភា ឆ្នាំ២០០៨, ទំព័រ ១៨, EN 00204355, KH 00187669។

[82] **E3/5800** កាំង ហ្កេកអ៊ាវ *ហៅ* ឌុច, ប្រតិចារឹក, ១៦ មិថុនា ២០០៩, ទំព័រ២៧, EN 00341984, (KH 00342773) ("ខ្ញុំសួរអស់ពីរលើកនេះហើយខាងលើឲ្យប្រគល់ទៅឲ្យមិត្ត ប៉ុន សួរ"); ទំព័រ៣០, EN 00341987, KH 00342775 ("ប៉ុន្តែលើកទីមួយ និងលើកទីពីរខ្ញុំ។ ដល់បានពីរលើកហ្នឹងហើយ មេឲ្យខ្ញុំប្រគល់ កុយ ធួន ទៅមិត្ត ប៉ុន សួរចម្លើយ។ ខ្ញុំប្រគល់។ ខ្ញុំលែងសួរអីនេះហើយ។")។

[83] **E3/1604** S-21 ចម្លើយសារភាពរបស់ កុយ ធួន, KH 00005709-00005832 (១៤ កុម្ភៈ ១៩៧៧ - ៤ មីនា ១៩៧៧); KH 00005844-00005993 (២-៣ កុម្ភៈ ១៩៧៧); KH 00006757-00006956 (១៨ កុម្ភៈ ១៩៧៧-៩ មេសា ១៩៧៧); KH 00005994-00006184 (១៩ កុម្ភៈ ១៩៧៧-៤ មីនា ១៩៧៧); **E3/1753** ចម្លើយសារភាព កុយ ធួន អំពី អំពីគណៈកម្មាធិការ

ផ្ទាល់នោះ ដូច្នេះ មានពាក់ព័ន្ធតិចតួចទៅនឹងការសម្រេចរបស់អង្គជំនុំជម្រះលើបញ្ហាថាតើមាន "ហានិភ័យពិតប្រាកដ" ដែលចម្លើយសារភាព នួន ជា ស្នើសុំប្រើប្រាស់នោះ បានមកពីការធ្វើទារុណកម្ម ឬអត់នោះទេ។

23. តាមពិត គឺច្បាស់តាមរយៈចម្លើយសារភាពដែលអាចរកបានថា ទាំងនេះគឺទទួលបានដោយការធ្វើទារុណកម្មលើរាងកាយ។ ជាឧទាហរណ៍ មានចំណារមួយនៅលើចម្លើយសារភាពរបស់ កុយ ធួន បានបញ្ជាក់យ៉ាងច្បាស់ថា "វាឆ្លើយពេលយើងចោះម្ខាង"[84]។ ចំណារមួយទៀត សរសេរថា "វាឆ្លើយពេលយើងចោះម្ខាងទៀត"[85]។ ស្រដៀងគ្នានេះ ចំណារដទៃទៀតបង្ហាញឲ្យឃើញពីចរិកបង្ខិតបង្ខំយ៉ាងខ្លាំងនៃការសួរចម្លើយ៖ "ពេលបងប្អូនដាក់ខ្នោះដៃ អាធួន ឆ្លៀតសរសេររឿងនេះទៀត។ វាសុំស្នើលែងខ្នោះដៃ ហើយដាក់តែ៣ថ្ងៃ បានហើយ។ "គាត់ នឹងសរសេររឿង ស/ម ញឹម & បងភឹម ឲ្យអស់"[86]។

24. តាមពិតនោះ ការអះអាងរបស់ នួន ជា ដែលថា "កុយ ធួន មិនត្រូវបានធ្វើទារុណកម្មដោយរូបគាត់ [ឌុច] ឬដោយអ្នកដទៃទៀត"[87] គឺជឿតាមសំដីរបស់ ឌុច ផ្ទាល់ ដែលថា៖

> *ឯករណី កុយ ធួន យើងធ្វើទារុណកម្ម ដោយសាររឿងប្រតិកម្ម...* យើងមើលទៅឃើញសេចក្តីសារភាពនឹងមិនពេញចិត្តយើង យើងវ៉ៃ។ នេះគេហៅថា 'ចម្លើយសារភាពចំពេក'... ខ្ញុំគិតនិយាយអំពីថាករណី កុយ ធួន ប្រើវិធីក្តៅ[88] នៅពេលដែលគាត់ធ្វើប្រតិកម្ម"[89]។

*យឹម សំបាត់*

ប្រឆាំងបដិវត្តនៅ ស.រ ឧត្តរមានជ័យ, EN 00178180 – 00178182, KH 00006182-00006183; **E3/3856** ចម្លើយសារភាពរបស់ កុយ ធួន *ហៅ* ឃួន, KH 00026253-00026318 (៥ កុម្ភៈ ១៩៧៧ - ៤ មីនា ១៩៧៧)។

[84] **E3/1604** សេចក្តីសារភាព ស-២១ របស់ កុយ ធួន, EN 00769831, KH 00006159។

[85] **E3/1604** សេចក្តីសារភាព ស-២១ របស់ កុយ ធួន, KH 00006930។

[86] **E3/1604** សេចក្តីសារភាព ស-២១ របស់ កុយ ធួន, EN 00773088, KH 00006757។

[87] **E399** សំណើរបស់ នួន ជា, កថាខណ្ឌ១៦។

[88] **E3/1570** កំណត់ហេតុនៃការសួរចម្លើយរបស់ កាំង ហ្គេកអ៊ាវ *ហៅ* ឌុច, ២៩ វិច្ឆិកា ២០០៧, EN 00154195, KH 00154224 ("*វិធីក្តៅមាន:* ការដេរស្តី ការវាយដំ និងការធ្វើទារុណកម្មផ្សេងទៀត")។

[89] **E3/347** បទសម្ភាសន៍ជាមួយ ឌុច ខែឧសភា ឆ្នាំ១៩៩៩, ទំព័រ 29-30, EN 00185024-00185025, KH 00160904-00160905 (សង្កត់ន័យបន្ថែមដោយ *អក្សរទ្រេត*)។

25. ពាក្យសុំរបស់ នួន ជា ស្នើសុំប្រើប្រាស់ចម្លើយសារភាពរបស់ យឹម សំបាត់[90] ដែលជាទាហានកងពលលេខ១៧០ ដែលបានសារភាពថាបានបោកគ្រាប់បែកដៃនៅព្រះបរមរាជវាំងនោះ[91] គឺផ្អែកលើសក្ខីកម្មរបស់ ឌុច ដែលថា តាមការណែនាំរបស់ សុន សេន ទារុណកម្មមិនត្រូវបានប្រើក្នុងអំឡុងពេលសួរចម្លើយគាត់នោះទេ[92]។ ក៏ប៉ុន្តែ សម្រាប់ហេតុផលនានាដែលបានរៀបរាប់ខាងលើ ទោះបីជាចម្លើយសារភាពនេះមិនត្រូវបានធ្វើឡើងដោយការប្រើអំពើហិង្សាផ្លូវកាយ ក្នុងអំឡុងពេលសួរចម្លើយក៏ដោយ ក៏លក្ខខណ្ឌនៃការឃុំខ្លួន និងការសួរចម្លើយនៅមន្ទីរ ស-២១[93] បង្ហាញថាមាន "ហានិភ័យពិតប្រាកដ" ដែលថាចម្លើយសារភាពរបស់ យឹម សំបាត់ គឺជាលទ្ធផលនៃការឈឺចាប់ និងការរងទុក្ខផ្លូវចិត្ត និងខាងរាងកាយដ៏ធ្ងន់ធ្ងរ។

26. សហព្រះរាជអាជ្ញាកត់សម្គាល់បន្ថែមទៀតថា វាគឺតាមរយៈការចាប់ខ្លួន និងការសួរចម្លើយជាបន្តបន្ទាប់ ដែលទារុណកម្មត្រូវបានសន្មតថាត្រូវបានប្រើ ដែលផែនការទាយស្មានដែលបានចោទប្រកាន់ ចក្រី និងអ្នកដទៃទៀត បានលិចឡើង[94]។ ចម្លើយសារភាពដែល នួន ជា ស្វែងរកដើម្បីពឹងផ្អែកលើនោះ រួមបញ្ចូល និងសេចក្តីសង្ខេបចម្លើយសារភាពរបស់អ្នកទោសផ្សេងទៀត បន្ថែមលើ យឹម សំបាត់ មានដូចជា សុខ សារិន, ធី ធឿន, សោម ថាន់ *ហៅ* ចក់ យន់[95] ដែលត្រូវបានសន្មតថាបានធ្វើឡើងតាមរយៈការធ្វើទារុណកម្ម ហើយមិនអាចត្រូវបានប្រើដោយ នួន ជា ដោយការយោងលើខ្លឹមសាររបស់ពួកវាបានឡើយ[96]។

---

[90] **E3/7397** ចម្លើយារភាពមន្ទីរស-២១ របស់ យឹម សំបាត់។

[91] **E3/7397** ចម្លើយារភាពមន្ទីរស-២១ របស់ យឹម សំបាត់, EN 00284003, KH 00245206។

[92] **E399** សំណើរបស់ នួន ជា, កថាខណ្ឌ ២០-២១, *យោងសម្អាង* **E3/356** កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្គេកអ៊ាវ *ហៅ* ឌុច, ២៥ វិច្ឆិកា ២០០៨, EN 00242900 និង **E319/42.3.1** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កាំង ហ្គេកអ៊ាវ *ហៅ* ឌុច, ១ កុម្ភៈ ២០១៦, ក ១៣។

[93] សូមអាន *កំណត់សម្គាល់ខាងដើម* លេខ ១៤-១៩។

[94] **E3/356** កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្គេកអ៊ាវ *ហៅ* ឌុច, ២៥ វិច្ឆិកា ២០០៨ ទំព័រ៦, EN 00242900 KH 00242889 ("ចម្លើយសារភាពរបស់គាត់ភ្ជាប់ជាមួយ រូបថតនោះផង ត្រូវបានបញ្ជូនទៅថ្នាក់លើ។ កិច្ចប្រជុំមួយ ត្រូវបានរៀបចំឡើងដោយមាន សុន សេន, សៀត ឆែ, ចាន់ ចក្រី, និងខ្លួនខ្ញុំ។ ចាន់ ចក្រី បាននិយាយថា យឹម សំបាត់ បានធ្វើតែម្នាក់ឯងទេ ដូច្នេះមិនចាំបាច់រកអ្នកទទួលខុសត្រូវផ្សេងទៀតទេ។ ប៉ុន្តែការចាប់ខ្លួនអ្នកផ្សេងទៀតត្រូវបានធ្វើ។ ហើយជាចុងក្រោយ ចាន់ចក្រីខ្លួនឯងត្រូវបានចាប់ខ្លួន។")។

[95] **E3/7397** ចម្លើយារភាពមន្ទីរស-២១ របស់ យឹម សំបាត់, EN 00284004, KH 00245207 ("សរុបចម្លើយ យឹម សំបាត់ សុខ សារិន ធី ធឿន [និង] សោម ថាន់ ហៅ ថន"); EN 00284005, KH 00245208 ("ចម្លើយសារភាពរបស់ ចក់ យន់)។

[96] សូមមើល *យោងខាងលើ* កថាខណ្ឌ៦, ៨។

*ជា នន់ (ជា ណុន) ហៅ ស្អួង*

27. នួន ជា ចង់ឲ្យប្រើកំណត់ហេតុស្តាប់ចម្លើយ ស្អួង ដែលជាលេខាកងពលធំ៤៥០ ដោយផ្អែកលើមូលដ្ឋាននៃចំណារមួយដែលមាននៅលើទំព័រដំបូងនៃកំណត់ហេតុមួយនៃកំណត់ហេតុស-២១របស់គាត់ ដែលបញ្ជាក់ថា បានសរសេរ មុនពេលគាត់ត្រូវបានគេធ្វើទារុណកម្ម[97]។ ដូចគ្នានឹងករណីឃឹម ដែរ ទោះបីជាចម្លើយសារភាពរបស់ ស្អួង មិនត្រូវបានគេទាញយកដោយប្រើដោយផ្ទាល់នូវអំពើហិង្សាលើរាងកាយក្នុងអំឡុងពេលសួរចម្លើយក៏ដោយ ក៏កាលៈទេសៈនៃការឃុំឃាំង និងការសួរចម្លើយនៅស-២១[98] មានន័យថាមាន "ហានិភ័យពិតប្រាកដ" ដែលថា ចម្លើយសារភាពទាំងនេះ ត្រូវទទួលបានតាមរយៈការប្រើទារុណកម្មខាងផ្លូវចិត្ត និងខាងរាងកាយ។

28. ជាងនេះទៀត នួន ជា ខកខានមិនបានទទួលស្គាល់ចំណារនេះទេ ដែលទាក់ទងតែកំណត់ហេតុដែលបានធ្វើឡើងដោយ ស្អួង នៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ១៩៧៧[99] ពេលដែលគាត់បានមកដល់ ស-២១ ប៉ុណ្ណោះ[100]។ នៅក្នុងកំណត់ហេតុនេះ ស្អួង អះអាងអំពីនិរទោស និងរៀបរាប់ពីសម្ព័ន្ធភាពរបស់គាត់ជាមួយ កុយ ធួន ប៉ុណ្ណោះ[101]។ ចំណារនេះ*មិន* សំដៅទៅលើចម្លើយសារភាពដែលនៅសេស

---

[97] **E399** សំណើរបស់ នួន ជា, កថាខណ្ឌ២៣-២៦ *យោង* ឯកសារ **E3/1892** ចម្លើយសារភាពនៅ ស-២១ របស់ ជា នន់ *ហៅ* ស្អួង, EN 00769596 ("ចម្លើយសារភាពនេះសរសេរដោយខ្លួនគាត់ មុនពេលធ្វើទារុណកម្ម")។ សូមមើលផងដេរ **E3/1892** S-21 Confession of Chea Non *alias* Suong, EN 00769596 ("This confession was written by him before being tortured")។ កំណត់ហេតុជាភាសាអង់គ្លេសនេះ យោងឯកសារខ្មែរដែលមានលេខ ERN KH 00012693, ដែលនៅក្នុងនោះមានកំណត់ហេតុស្រដៀង។

[98] សូមអាន កថាខណ្ឌ ១៤-១៩ *ខាងលើ*។

[99] **E3/1892** ចម្លើយសារភាពនៅ ស-២១ របស់ ជា នន់ *ហៅ* ស្អួង, លេខាកងពលធំ ៤៥០, KH 00012694-00012698។ នៅលើទំព័រនិមួយៗនៃចម្លើយសារភាពនេះ មានចំណារចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ១៩៧៧។ សូមមើលផងដែរ EN 00096949 ("ឯកសារសរសេរដោយដៃចំនួនប្រាំមួយទំព័រ ចុះថ្ងៃទី២០ កុម្ភៈ ១៩៧៧ នៅគែមទំព័រ")។

[100] **E393.2** បញ្ជីអ្នកទោស ស-២១ របស់ កសចស ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៦, ត្រង់លេខ ៤៣៣ (ថ្ងៃចូល ស-២១: ១៩ កុម្ភៈ ១៩៧៧)។

[101] **E3/1892** ចម្លើយសារភាពនៅ ស-២១ របស់ ជា នន់ *ហៅ* ស្អួង, លេខាកងពលធំ ៤៥០, EN 00096949, KH 00012693-00012698 ("ក្រោយរំដោះហើយ នៅពេល វា [ឃួន] បំផុសឲ្យគិតតែពីសប្បាយ ផឹកស៊ី ស្រីញី។ តែខ្ញុំផ្ទាល់ ឥតចេះផឹកស្រាបីយែរទេ ស្រីញីក៏មិនដែលទាក់ទងរហោតរហូតដែរ។ ខ្ញុំបញ្ជាក់ជូនអង្គការដោយស្មោះ ហើយអង្គការមិនជឿ អង្គការតាមដានក្នុងកងចុះ។... ចំពោះសកម្មភាពរបស់ខ្ញុំ អត់មានចូលបក្សខ្មែរសេរី ឬបក្សសេរីរើទេ គ្រាន់តែមានការទាក់ទងជាមួយឈ្មោះ ឃួន ហើយមិនដឹងឈ្មោះ ឃួន ជាខ្មែរសេរីទេ...")។ សហព្រះរាជអាជ្ញា សង្កេតឃើញថាកំណត់ហេតុនេះអះអាងពីនិរទោសរបស់

សល់ទេ[102] ដែលត្រូវបានគេសន្មតថា បានទទួលតាមរយៈការធ្វើទារុណកម្ម[103]។ នួន ជា ត្អូញត្អែរថា អង្គជំនុំជម្រះធ្លាប់បដិសេធពីមុនមិនឱ្យគាត់ឆ្លើយតបទៅនឹងចម្លើយសារភាពរបស់ ស្នួង នេះទេ[104] និងបានស្នើឱ្យមានការពិចារណាឡើងវិញចំពោះសេចក្តីសម្រេចរបស់ខ្លួន[105]។ ប៉ុន្តែ វាក្យខណ្ឌដែលមេធាវីការពារក្តី នួន ជា បានស្នើឱ្យដកស្រង់នៅក្នុងឧទាហរណ៍នោះ ហាក់ដូចជាចេញមកពីផ្នែកផ្សេងនៃចម្លើយសារភាពចុងក្រោយរបស់ ស្នួង ទៅវិញ[106] គឺមិនមែននៅត្រង់ផ្នែក

---

ជនជាប់ចោទ មិនមែនជាចម្លើយសារភាពមួយដែលបានមកពីការធ្វើទារុណកម្ម ដែលត្រូវបានហាមឃាត់ដោយអនុសញ្ញាអន្តរជាតិស្តីពីការប្រឆាំងនឹងការធ្វើទារុណកម្មនោះទេ។

[102] ទាំងអស់នេះចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ១៩៧៧ (**E3/1892** ចម្លើយសារភាពនៅ ស-២១ របស់ ជា នន់ *ហៅ* ស្នួង, លេខាកងពលធំ ៤៥០, KH 00012699-00012705); ២៣-២៨ មីនា ១៩៧៧ (**E3/1892** ចម្លើយសារភាពនៅ ស-២១ របស់ ជា នន់ *ហៅ* ស្នួង, លេខាកងពលធំ ៤៥០, KH 00012706-00012761); ៩-១១ មេសា ១៩៧៧ (**E3/1892** ចម្លើយសារភាពនៅ ស-២១ របស់ ជា នន់ *ហៅ* ស្នួង, លេខាកងពលធំ ៤៥០, KH 00012763-00012794, 00012865-00012866)); ១៣-១៦ មេសា ១៩៧៧ (**E3/1892** ចម្លើយសារភាពនៅ ស-២១ របស់ ជា នន់ *ហៅ* ស្នួង, លេខាកងពលធំ ៤៥០, KH 00012796-00012825); ២១-២៣ មេសា ១៩៧៧ (**E3/1892** ចម្លើយសារភាពនៅ ស-២១ របស់ ជា នន់ *ហៅ* ស្នួង, លេខាកងពលធំ ៤៥០, KH 00012827-00012864); ២៧-២៨ មេសា ១៩៧៧ (**E3/1892** ចម្លើយសារភាពនៅ ស-២១ របស់ ជា នន់ *ហៅ* ស្នួង, លេខាកងពលធំ ៤៥០, KH 00012868-00012882), ២៨-២៩ មេសា ១៩៧៧ (**E3/1892** ចម្លើយសារភាពនៅ ស-២១ របស់ ជា នន់ *ហៅ* ស្នួង, លេខាកងពលធំ ៤៥០, KH 00012913-00012921); ២៧-៣០ មេសា-២ ឧសភា ១៩៧៧ (**E3/1892** ចម្លើយសារភាពនៅ ស-២១ របស់ ជា នន់ *ហៅ* ស្នួង, លេខាកងពលធំ ៤៥០, KH 00012890-00012912, 00012922-00012923); ៣-៤ ឧសភា ១៩៧៧ (**E3/1892** ចម្លើយសារភាពនៅ ស-២១ របស់ ជា នន់ *ហៅ* ស្នួង, លេខាកងពលធំ ៤៥០, KH 00012925-00012943); ១០ ឧសភា ១៩៧៧ (**E3/1892** ចម្លើយសារភាពនៅ ស-២១ របស់ ជា នន់ *ហៅ* ស្នួង, លេខាកងពលធំ ៤៥០, KH 00012945-00012957)។

[103] សូមមើលកំណត់សម្គាល់ខាងដើម កថាខណ្ឌ៨។

[104] **E399** សំណើរបស់ នួន ជា, កថាខណ្ឌ២៣-២៦ យោងឯកសារ **E1/318.1** ប្រតិចារឹក ១៧ មិថុនា ២០១៥, ទំព័រ៧៩-៨២ និងឯកសារ **E350/8** សេចក្តីសម្រេចស្តីពីការធ្វើទារុណកម្មរបស់ អជសដ, កថាខណ្ឌ៨៦។

[105] **E399** សំណើរបស់ នួន ជា, កថាខណ្ឌ២៩។

[106] ក្នុងសាលសវនាការ មេធាវីការពារក្តី នួន ជា បានស្នើសុំអានជូនដើមបណ្តឹងរដ្ឋប្បវេណី នូវសម្រង់មួយចេញពីផ្នែកនៃចម្លើយសារភាពរបស់ ស្នួង "ជាពិសេសអំពីមន្ទីរពេទ្យកងពលធំ" (**E1/318.1** ប្រតិចារឹក ១៧ មិថុនា ២០១៥, ទំព័រ៨០ យោងច្បាប់បកប្រែជាភាសាអង់គ្លេសនៃឯកសារ **E3/1892** ចម្លើយសារភាពនៅ ស-២១ របស់ ជា នន់ *ហៅ* ស្នួង, ត្រង់ ERN 00096949)។ សហព្រះរាជអាជ្ញាកត់សម្គាល់ថា ការយោងអំពី"មន្ទីរពេទ្យកងពលធំ" មានតែនៅក្នុងច្បាប់បកប្រែជាភាសាអង់គ្លេសនៃឯកសារ **E3/1892** បង្ហាញនៅត្រង់ EN 00096953, 00096966, 00069670 ប៉ុណ្ណោះ ដែលទាំងអស់នេះស្ថិតក្នុងទម្រង់នៃចម្លើយសារភាពរបស់ ស្នួង ចុះខែមីនា និងមេសា ១៩៧៧។

នៃកំណាត់ហេតុដំបូងដែលទទួលបាននៅមុនការប្រើប្រាស់ទារុណកម្មផ្ទាល់នោះទេ ក្នុងពេលធ្វើទារុណកម្ម។ ដូច្នេះ សំណើរបស់ នួន ជា សុំឲ្យពិចារណាឡើងវិញ គឺគ្មានមូលដ្ឋានទេ។

## *កិច្ចស៊ើបសួរបន្ថែម*

29. អនុលោមតាមវិធាន៩៣(១) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះ*អាច* ដឹកនាំកិច្ចស៊ើបសួរបន្ថែម ប្រសិនបើខ្លួនយល់ថាចាំបាច់[107]។ តាមស្មារតីនៃភ័ស្តុតាងទាំងអស់ដែលបង្ហាញឲ្យឃើញពី "ហានិភ័យពិតប្រាកដ" ដែលថាចម្លើយសារភាព ស-២១ របស់ កុយ ធួន, យឹម សំបាត់ និង សួង គឺទទួលបានតាមរយៈការធ្វើទារុណកម្មនោះ សហព្រះរាជអាជ្ញាសន្និដ្ឋានថា កិច្ចស៊ើបសួរបន្ថែមពីកាលៈទេសៈដែលកំណត់ហេតុត្រូវបានធ្វើឡើង មិនចាំបាច់ទេ។ អង្គជំនុំជម្រះគ្មានកាតព្វកិច្ចដឹកនាំកិច្ចស៊ើបសួរណាមួយនៅក្រោមវិធាន៩៣(១)នេះទេ ដូចដែលវិធាននេះបញ្ជាក់យ៉ាងច្បាស់ថា សេចក្ដីសម្រេចដូច្នេះត្រូវផ្អែកលើឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះ ហើយសហព្រះរាជអាជ្ញាក៏សន្និដ្ឋានផងដែរថាវាមិនមែនជាការប្រុងប្រយ័ត្នក្នុងប្រើប្រាស់ពេលវេលា និងធនធាន ដើម្បីដឹកនាំកិច្ចស៊ើបសួរបន្ថែមនោះ ជាពិសេស មានការពន្យារពេលដែលមិនអាចចៀសរួចសម្រាប់កិច្ចដំណើរការនីតិវិធី និងអង្គហេតុដែលថាកន្លែងល្អបំផុតក្នុងការចង់ដឹងអំពីកាលៈទេសៈទាំងនោះ នៅជុំវិញការសួរចម្លើយទាំងនេះ - គឺបុគ្គលដោយខ្លួនឯង - ដែលឥឡូវនេះបានទទួលមរណភាព ត្រូវបានសម្លាប់ក្រោយមានចម្លើយសារភាពរបស់ពួកគាត់។

## IV. **ដំណោះស្រាយដែលស្នើឡើង**

30. ដោយមានការលើកលែងលើការអនុញ្ញាត ប្រើប្រាស់កំណត់ហេតុនៅ ស-២១ ក្នុងគោលបំណងមានកម្រិត ដូចចែងនៅក្នុងកថាខណ្ឌ ២ និង ៦ ខាងលើ សហព្រះរាជអាជ្ញាសូមស្នើឲ្យអង្គជំនុំជម្រះសាលាដំបូង ច្រានចោលសំណើសុំនេះ៕

| **កាលបរិច្ឆេទ** | **ឈ្មោះ** | **ទីកន្លែង** | **ហត្ថលេខា** |
|---|---|---|---|
| ថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៦ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | [signature] |
| | **លោក Nicholas KOUMJIAN**<br>សហព្រះរាជអាជ្ញា | | [signature] |

[107] សង្កតន័យត្រង់*អក្សរទ្រេត*។